អង្គការសហគមន៍ឥន្ទធនូកម្ពុជា

ROCK

RAINBOW COMMUNITY KAMPUCHEA
ORGANISATION

# មគ្គុទេសក៍ស្ដីពីសិទ្ធិមនុស្ស
# សម្រាប់អ្នកស្រឡាញ់ភេទដូចគ្នា
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា



អង្គការសហគមន៍ឥន្ធនូកម្ពុជា
RoCK
RAINBOW COMMUNITY KAMPUCHEA ORGANISATION

# មាតិកា

RAINBOW COMMUNITY KAMPUCHEA ORGANISATION


ទំព័រ 02 អារម្ភកថា

ទំព័រ 03 សន្ទានុក្រម

ទំព័រ 05 សេចក្តីផ្តើម

ទំព័រ 07 និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ (ពាក្យកាត់ “សូជី”)

ទំព័រ 10 សិទ្ធិរបស់អ្នក

ទំព័រ 31 កម្រងមាត្រានៃច្បាប់ជាតយោងទៅតាមសិទ្ធិនីមួយៗ

# អារម្ភកថា

អង្គការសហគមន៍ឥន្ទធនូកម្ពុជា (រ៉ក់) និង អង្គការគោលដៅយុត្តិធម៌ សូមថ្លែងអំណរគុណជាអនេកប្បការដល់ក្រុមការងាររបស់យើងនៅក្នុងចូលរួមការស្រាវជ្រាវ ការរៀបរៀង និងបកប្រែសៀវភៅមគ្គុទ្ទេសក៏សិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នានេះ។ អង្គការទាំងពីរសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅទៅដល់ភាគីទាំងអស់ ដែលបានជំរុញឲ្យមានការទទួលស្គាល់នូវសៀវភៅមគ្គុទ្ទេសក៏នេះ ក៏ដូចជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជាផងដែរ។

# សន្ទទានុក្រម

អ្នកស្រឡាញ់ភេទដូចគ្នា៖ ជាពាក្យបច្ចេកទេស ដែលបាន និងកំពុងប្រើប្រាស់ ដើម្បី បង្ហាញនូវភាពទូលំទូលាយរបស់បុគ្គល ដែលមានមនោសញ្ចេតនាស្នេហា ជាមួយបុគ្គលផ្សេងទៀត ដែលមានភេទ ឬ អត្តសញ្ញាណយេនឌ័រចម្រុះដូចជាស្ត្រី ស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ ជាដើម។

ស្ត្រីស្រឡាញ់ស្ត្រី៖ ពាក្យនេះប្រើ សម្រាប់ពិពណ៌នា ពីស្ត្រីដែលបានកំណត់ មនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញស្នេហាជាមួយស្ត្រី។
បុរសស្រឡាញ់បុរស៖ ពាក្យនេះប្រើសម្រាប់ពិពណ៌នា ពីបុរសដែលបានកំណត់ មនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញស្នេហាជាមួយបុរស។
អ្នកស្រឡាញ់ភេទទាំងពីរ៖ ពាក្យនេះប្រើសំដៅទៅលើ បុគ្គលដែលមានមនោសញ្ចេតនា ឬ អារម្មណ៍ទាក់ទាញស្នេហាជាមួយបុរសផង និងស្ត្រីផង។
អ្នកប្តូរយេនឌ័រ៖បុគ្គលដែលកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួនឯងតាមរយៈការ បង្ហាញខាងក្រៅ ដូចជាការស្លៀកពាក់ និងអាកប្បកិរិយា ដែលផ្ទុយពីភេទកំណើត របស់ខ្លួន។
អន្តរភេទ៖ ប្រើសម្រាប់ពិពណ៌នា បុគ្គលដែលកើតមកមានលក្ខណៈកត្តាជីវសាស្ត្រ លាយឡំគ្នានៃភេទប្រុស និងស្រី រួមបញ្ចូលទាំងអ័រម៉ូន ក្រូម៉ូសូម និងរូបរាងកាយ។
អត្តសញ្ញាណយេនឌ័រ៖ ការកំណត់ខ្លួនឯង ដោយផ្អែកលើអារម្មណ៍ខាងក្នុងយ៉ាង ជ្រាលជ្រៅអំពីយេនឌ័រ ដែលអាចស្រប ឬ ផ្ទុយពីភេទកំណើតរបស់បុគ្គល។
ការបង្ហាញយេនឌ័រ៖ ការបង្ហាញឲ្យឃើញ ពីរូបរាងខាងក្រៅ នៃយេនឌ័ររបស់បុគ្គល ម្នាក់តាមរយៈការស្លៀកពាក់ អាកប្បកិរិយា ឥរិយាបថ សម្លេង ឈ្មោះ ដើម្បីកំណត់ អត្តសញ្ញាណខ្លួនឯង ដែលផ្ទុយពីភេទកំណើត។

**និន្នាការភេទ៖** សំដៅលើទំនោរ ឬ មនោសញ្ចេតនា ឬ អារម្មណ៍ស្នេហារបស់បុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតដែលមានអត្តសញ្ញាណយេនឌ័រ និងភេទផ្សេង។

**អ្នកមិនកំណត់អត្តសញ្ញាណភេទខ្លួនឯង៖** បុគ្គលដែលមានអត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័ររបស់ខ្លួន មិនស្របទៅតាមការកំណត់ និយមន័យនៃភេទប្រុស និងភេទស្រី។ បុគ្គលទាំងនេះអាចកំណត់អត្តសញ្ញាណយេនឌ័ររបស់ខ្លួននៅចន្លោះរវាង ឬ ក្រៅពីបុរស និងស្ត្រី។

**យេនឌ័រទ្វេភាគ៖** ជាប្រព័ន្ធមួយដែលភេទ និងយេនឌ័រត្រូវបានចាត់ថ្នាក់ជាពីរប្រភេទប៉ុណ្ណោះគឺ ប្រុស និងស្រី។ អ្នកស្រឡាញ់ភេទដូចគ្នា ជាច្រើននាក់ចាត់ទុកប្រព័ន្ធនេះជាការរឹតត្បិត និងគាបសង្កត់។

**សូជី៖** ពាក្យកាត់នៃភាសាអង់គ្លេស ដែលពាក្យ និងអត្ថន័យពេញលេញគឺ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។

**រដ្ឋធម្មនុញ្ញ៖** ជាច្បាប់កំពូលនៃប្រទេសមួយ។ រដ្ឋធម្មនុញ្ញរៀបចំជីវិតនៃរដ្ឋមួយ។ ជាពិសេស វាកំណត់សិទ្ធិ និងការទទួលខុសត្រូវ ចំពោះប្រជាពលរដ្ឋ ហើយបង្កើតស្ថាប័នដែលធានានូវសិទ្ធិនិងករណីកិច្ចរបស់ប្រជាពលរដ្ឋអោយមានប្រសិទ្ធភាព។

**គោលការណ៍យ៉កយ៉ាកាតា៖** គោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ គោលការណ៍នេះ ត្រូវបានបង្កើត និងអនុលោមនៅសន្និបាតអន្តរជាតិរបស់ក្រុមអ្នកធ្វើការផ្នែកសិទ្ធិមនុស្សប្រព្រឹត្តិទៅនៅខែវិច្ឆិកា ឆ្នាំ២០០៦ ក្នុងទីក្រុងយ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី។



# សេចក្ដីផ្ដើម

មគ្គុទ្ទេសក៍សិទ្ធិមនុស្សរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា (ប្រើពាក្យខ្លីថា "មគ្គុទ្ទេសក៍")។ មគ្គុទ្ទេសក៍នេះ គឺជាលទ្ធផលមួយ នៃកិច្ចសហប្រតិបត្តិការរវាងអង្គការសហគមន៍ឥន្ទធនូកម្ពុជា និងគម្រោងយុត្តិធម៌ឥន្ទធនូរបស់អង្គការគោលដៅយុត្តិធម៌ ក្នុងគោលបំណងបង្កភាពងាយស្រួលដល់បុគ្គលគ្រប់រូបទទួលបានព័ត៌មានផ្អែកច្បាប់ជាមូលដ្ឋាន ដែលពាក់ព័ន្ធនឹងសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

មនុស្សគ្រប់រូបសុទ្ធតែមាន ចរិតលក្ខណៈរួមមួយ គឺយើងទាំងអស់គ្នាសុទ្ធតែមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ខ្លួន។ មិនថាបុគ្គលនោះជាស្ត្រីស្រឡាញ់ភេទដូចគ្នា បុរសស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ អ្នកស្រឡាញ់ភេទផ្ទុយគ្នា និងមិនថាអ្នកកំណត់អត្តសញ្ញាណ របស់អ្នកជាស្ត្រី ឬបុរស អ្នកប្តូរយេនឌ័រ ឬ អន្តរភេទឡើយ។ សិទ្ធិមនុស្សគឺសម្រាប់គ្រប់គ្នាដោយគ្មានការរើសអើង។ ទោះបីជាមគ្គុទ្ទេសក៍នេះត្រូវបានបង្កើតឡើង សម្រាប់ប្រជាជនដែលជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទអ្នកប្តូរយេនឌ័រ និងអ្នកកំពុងស្ថិតនៅដំណាក់កាលកំណត់យេនឌ័របស់ខ្លួន (ហៅកាត់ថា "អិល.ជី.ប៊ី.ធី.អាយ.ឃ្យូ" ឬ "LGBTIQ") ក៏ដោយ តែបទបញ្ញត្តិ ទាំងនេះអនុវត្តសម្រាប់បុគ្គលគ្រប់រូប។

មគ្គុទ្ទេសក៍នេះមានគោលបំណង ពង្រឹងភាពម្ចាស់ការ ដល់សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងការអះអាងនូវសិទ្ធិឯកជននីមួយៗ ដែលត្រូវបានផ្តល់និងធានាដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ វាគឺឯកសារក្នុងន័យជាព័ត៌មាន និងចំណេះដឹងដ៏មានអត្ថប្រយោជន៍ សម្រាប់បុគ្គលគ្រប់រូប មិនមែនប្រើដើម្បីតតាំងនៅចំពោះមុខច្បាប់ និងតុលាការនោះទេ។ មគ្គុទ្ទេសក៍នេះជាឧបករណ៍មួយសម្រាប់អ្នកដឹកនាំសហគមន៍ អ្នកស្រឡាញ់ភេទដូចគ្នាទាំងអស់ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ទុកជាជំនួយសម្រាប់ពួកគេ អះអាងពីសិទ្ធិរបស់ខ្លួនឲ្យបានទូលំទូលាយ និងមានប្រសិទ្ធភាព។

មគ្គុទ្ទេសក៍នេះត្រូវបានបែងចែកជាពីរផ្នែកៈ
១.ការបង្ហាញពី និន្នាការភេទការកំណត់ យេនឌ័រ និងការបង្ហាញអត្តសញ្ញាណយេនឌ័រ ព្រមទាំងមូលដ្ឋានច្បាប់សម្រាប់សិទ្ធិមនុស្ស។

២.សេចក្តីពន្យល់លម្អិតអំពីសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា ដែលពាក់ព័ន្ធនឹងការប្រើ អំពើហិង្សាជាសាធារណៈ ការរំលោភបំពានប្រចាំថ្ងៃ និងរឿងរ៉ាវពិតមួយចំនួន ក្នុងបរិបទដែលប្រទេសកម្ពុជា កំពុងអភិវឌ្ឍន៍នូវការធានាឲ្យមានសិទ្ធិស្មើគ្នាសម្រាប់បុគ្គលគ្រប់រូប ដែលមានភាពចម្រុះនៃ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។




*©រ៉ក់, ទិវាសិទ្ធិមនុស្សអន្តរជាតិ ២០១៨*

# និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ (ពាក្យកាត់ "សូជី")

ដើម្បីបញ្ជាក់ឲ្យកាន់តែយល់ច្បាស់បន្ថែមពីនិយមន័យខាងលើ សូមពិនិត្យមើលនូវឧទាហរណ៍ដូចខាងក្រោម៖

អត្តសញ្ញាណយេនឌ័រ៖ អ្នកប្តូរយេនឌ័រពីបុរសទៅជាស្ត្រីម្នាក់បានកើតមកមានភេទកំណើត និងរូបរាងកាយជាមនុស្សប្រុស។ ប៉ុន្តែគាត់មានអារម្មណ៍នៅខាងក្នុងយ៉ាងជ្រាលជ្រៅ នៃធម្មជាតិរបស់គាត់គឺជាមនុស្សស្រីពិតប្រាកដម្នាក់។ អ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស បានកើតមកមានភេទពីកំណើត និងរូបរាងកាយជាមនុស្សស្រី។ ប៉ុន្តែអារម្មណ៍នៅខាងក្នុង ដ៏ជ្រាលជ្រៅនៃធម្មជាតិរបស់គាត់គឺជាមនុស្សប្រុសយ៉ាងពិតប្រាកដ។ ការបង្ហាញយេនឌ័រ៖ ជាទូទៅអ្នកប្តូរយេនឌ័រពីស្រីទៅប្រុសស្លៀកសម្លៀកបំពាក់ តុបតែងខ្លួន និយាយសំដីសំដៅ និងរៀបឫកពារធ្វើយ៉ាងណាឲ្យដូចជាមនុស្សស្រី ដែលសង្គមកំណត់។

រីឯអ្នកប្តូរយេនឌ័រពីស្រីទៅប្រុសវិញ ធ្វើយ៉ាងណាបង្ហាញខ្លួនឲ្យដូចជាប្រុស ដែលសង្គមកំណត់។

និន្នាការភេទ៖ បុគ្គលម្នាក់មានអារម្មណ៍ និងមនោសញ្ចេតនានៃសេចក្តីស្នេហាជាមួយបុគ្គលម្នាក់ទៀត ដែលអាចជាបុរស ស្ត្រី ឬ អ្នកប្តូរយេនឌ័រ។ នេះមិនមែនមានន័យបុរសប្តូរយេនឌ័រទៅជាស្ត្រីសុទ្ធ តែមានមនោសញ្ចេតនាស្នេហាជាមួយតែបុរស ហើយស្ត្រីប្តូរយេនឌ័រទៅជាបុរសសុទ្ធតែមានសេចក្តីស្រឡាញ់ចំពោះតែស្ត្រីនោះទេ។ វាអាស្រ័យទៅលើនិស្ស័យ និងមនោសញ្ចេតនាស្នេហាពីធម្មជាតិដែលជាសេចក្តីពិត នៅខាងក្នុងដួងចិត្តរបស់ខ្លួន បើទោះបីជាសង្គមកំណត់ ឬរំពឹងថា ខ្លួនជាស្ត្រីត្រូវតែស្រឡាញ់បុរស ហើយបុរសត្រូវតែស្រឡាញ់ស្ត្រីក៏ដោយ។ ជាក់ស្តែងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ បានបង្កើតវិសាលភាព និងជាចរិតលក្ខណៈរួមនៃមនុស្សគ្រប់គ្នា មិនមែនចំពោះតែបុគ្គលដែលបានកំណត់ខ្លួនឯងជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរសអ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរ យេនឌ័រ ឬ អ្នកកំពុងស្វែងយល់ពីយេនឌ័រខ្លួននោះទេ។ បុគ្គលដែល

ជាអ្នកស្រឡាញ់ភេទដូចគ្នា ប្រហែលជាមានភាពភ័យខ្លាច នឹងការរើសអើង ការមាក់ងាយ និងការស្អប់ខ្ពើម ដោយសារតែអត្តសញ្ញាណយេនឌ័រ និងនិន្នាការភេទរបស់ពួកគេស្ថិតនៅក្នុងទិដ្ឋភាព ជាច្រើននៃជីវិតរបស់ពួកគេ។ ផ្នែកទាំងនោះរួមមានការទទួលបានការអប់រំ ការថែទាំសុខភាព ការងារ អាពាហ៍ពិពាហ៍ និងផ្នែកដទៃទៀត។ នៅខណៈពេលដែលក្របខ័ណ្ឌច្បាប់នៃប្រទេសកម្ពុជា មិនអនុញ្ញាតឲ្យមានការរើសអើងនូវគ្រប់ទម្រង់ ប៉ុន្តែក៏មិនមានបទប្បញ្ញត្តិណាមួយ ដែលចែងដើម្បីដោះស្រាយបទល្មើសពាក់ព័ន្ធទម្រង់នៃការរើសអើង ដោយផ្អែកលើអត្តសញ្ញាណយេនឌ័រ និងនិន្នាការផ្លូវភេទ របស់បុគ្គល ដែលអ្នកស្រឡាញ់ភេទដូចគ្នានៅឡើយដែរ។



*©រ៉ក់, ការដង្ហែរផ្កាប្រាក់សាមគ្គីសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាឆ្នាំ២០២០*

# សិទ្ធិមនុស្សនៅប្រទេសកម្ពុជា

សិទ្ធិមនុស្សផ្តោតទៅលើការការពារ និងសេរីភាពរបស់មនុស្សម្នាក់ៗដែលទទួលបានដើម្បីរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរស្មើភាពគ្នា និងដោយការគោរព។ បុគ្គលគ្រប់រូប ត្រូវបានផ្តល់នូវសិទ្ធិមនុស្ស។ លោកស្រី ហៀលឡារី រ៉ូដាម គ្លីនតុន (Hillary Rodham Clinton) ក្នុងឋានៈជារដ្ឋលេខាធិការ នៃក្រសួងការបរទេសសហរដ្ឋអាមេរិកបានបញ្ជាក់យ៉ាងច្បាស់នៅត្រង់ចំណុចនេះថា សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា គឺជាសិទ្ធិមនុស្ស ហើយសិទ្ធិមនុស្សគឺជាសិទ្ធិ របស់អ្នកស្រឡាញ់ភេទដូចគ្នា»។

សិទ្ធិមនុស្សត្រូវបានធានា ដោយសេចក្តីប្រកាស ជាសាកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័ត ដោយអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។សិទ្ធិទាំងនោះក៏បានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផងដែរ ជាពិសេសនៅក្នុងចំណុចបុព្វកថា និងមាត្រា៣១។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់យ៉ាងពិតប្រាកដថា សន្ធិសញ្ញាស្តីពីសិទ្ធិមនុស្សទាំងអស់ ដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា ត្រូវតែអនុវត្តផ្ទាល់នៅក្នុងប្រទេសកម្ពុជា។ នេះមានន័យថា សិទ្ធិទាំងនោះដែលមាននៅក្នុងអនុសញ្ញាអន្តរជាតិទាំងអស់ត្រូវបានធានាសម្រាប់ប្រជាជនកម្ពុជា។ ហេតុដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា មានកាតព្វកិច្ចការពារសិទ្ធិមនុស្សដោយផ្អែកទៅលើកត្តា ៣ សំខាន់ៗ នៃលិខិតតុបករណ៍ ដែលមានដូចជា៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ និងបទបញ្ជានៃព្រះរាជាណាចក្រកម្ពុជា
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធដទៃទៀតដែលរាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខា។

លើសពីនេះទៅទៀត អ្នកជំនាញផ្នែកសិទ្ធិមនុស្សអន្តរជាតិមួយចំនួនបានធ្វើសន្និបាតមួយនៅទីក្រុងយ៉កយ៉ាកាតា ប្រទេសឥណ្ឌូនេស៊ី ក្នុងឆ្នាំ២០០៦ ដើម្បីរៀបចំតាក់តែងគោលការណ៍អន្តរជាតិមួយកញ្ចប់ ដែលទាក់ទងនឹងច្បាប់អន្តរជាតិ

ស្តីពីសិទ្ធិនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។ អ្នកជំនាញទាំងនោះបាន អនុម័តគោលការណ៍យ៉ុកយ៉ាកាតា ដើម្បីបញ្ជាក់បន្ថែមអំពីច្បាប់អន្តរជាតិដែលនៅមានកម្រិត ហើយជំរុញឲ្យរដ្ឋទាំងអស់ត្រូវតែប្រតិបត្តិតាម។

# សិទ្ធិរបស់អ្នក

នៅក្នុងចំណុចនេះអ្នកនឹងស្វែងយល់នូវសិទ្ធិមួយចំនួនដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹង សហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា ព្រមទាំងសេចក្តីពន្យល់អំពីសិទ្ធិនីមួយៗ។ សិទ្ធិមនុស្សមួយចំនួនត្រូវបានលើកលែង និងត្រូវកំណត់ប្រសិទ្ធភាពនៃសិទ្ធិទាំងនោះ នៅក្នុងកាលៈទេសៈដែលប្រទេសជាតិមានសង្គ្រាម។ ដូច្នេះការដកហូតសិទ្ធិរបស់អ្នកដោយប្រើមូលហេតុថា អ្នកគឺជាមនុស្សនៅក្នុងសហគមន៍នៃអ្នកស្រឡាញ់ភេទដូចគ្នា គឺត្រូវបានហាមឃាត់ជាដាច់ខាត។ ម្យ៉ាងវិញទៀត និន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកនឹងមិនបាត់បង់ ដោយសារតែការដកហូតសិទ្ធិណាមួយរបស់អ្នក ដែលត្រូវបានផ្តល់អោយក្នុងនាមជាមនុស្សម្នាក់នោះដែរ។

# សិទ្ធិមិនទទួលរងការរើសអើង

សិទ្ធិដំបូង និងសិទ្ធិមូលដ្ឋាន ដែលអ្នកមាន គឺជាសិទ្ធិដែលអ្នកមិនត្រូវបានគេរើសអើង ប្រឆាំងនឹងអ្នក ដោយផ្អែកលើមូលដ្ឋាន នៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកនោះទេ។ វាមានន័យថា៖

- គ្មាននរណាម្នាក់ អាចចាត់ទុកអ្នកខុសពីអ្នកដទៃ ដោយផ្អែកលើមូលដ្ឋាននៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកនោះទេ។
- ច្បាប់ត្រូវតែធានាថា អ្នកត្រូវបានគេផ្តល់ការគោរពស្មើគ្នា ជាមនុស្សនៅក្នុងសង្គម។
- អាជ្ញាធរកម្ពុជាត្រូវធានាថានឹងចាត់វិធានការដើម្បី ធានាសិទ្ធិរបស់អ្នកពិតប្រាកពិសេស ដូចជាក្នុងវិស័យអប់រំ ការថែទាំសុខភាព និងការងារ។

សិទ្ធិមិនទទួលបានការរើសអើងដើរតួនាទីដូចជាផ័ត្រមួយ។ មានន័យថា សិទ្ធិនេះអាចឆ្លើយតបទៅនឹង សិទ្ធិដទៃទៀតដើម្បីធានាបាន នូវសិទ្ធិមនុស្សរបស់អ្នកទាំងមូល។ ឧទាហរណ៍បុគ្គលគ្រប់រូបត្រូវបានផ្តល់ឲ្យនូវ សិទ្ធិរស់រានមានជីវិត។ ហើយសិទ្ធិរស់រានមានជីវិត មិនត្រូវបានដកហូតពីអ្នក ដោយសារតែអ្នកបង្ហាញថា ខ្លួនជាស្ត្រីស្រឡាញ់ស្ត្រី ជាបុរសស្រឡាញ់បុរស អ្នកស្រឡាញ់ភេទទាំងពីរ អ្នកប្តូរយេនឌ័រ អន្តរភេទ ឬ អ្នកស្រឡាញ់ភេទផ្ទុយគ្នានោះទេ។ ក្នុងនាមជាមនុស្សម្នាក់ អ្នកមាន សិទ្ធិរស់រានមានជីវិត ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រឡើយ។

*« ខ្ញុំគឺជាគ្រូបង្រៀនម្នាក់ ជាអ្នកប្តូរយេនឌ័រពីស្រីទៅប្រុសដែលប្រតិព័ទ្ធមនុស្សស្រីដូចគ្នា។ ខ្ញុំជាឪពុកជាទីស្រលាញ់របស់កូន៥នាក់ ដែលខ្ញុំ និងប្រពន្ធរបស់ខ្ញុំបានសុំមក ចិញ្ចឹមបីបាច់ថែរក្សា។ អ្នកធ្វើការជាមួយខ្ញុំមួយចំនួនដឹងអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំ ប៉ុន្តែពួកគេមិនរើសអើងខ្ញុំនោះទេ ទោះបីនៅពេលបង្រៀនសិស្ស ខ្ញុំមិនស្លៀកសំពត់ដូចដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង របស់សាលាក៏ដោយ។ អ្វីដែលសំខាន់សម្រាប់ខ្ញុំ គឺគុណភាពការងាររបស់ខ្ញុំ។ »*

*............................................................................................. សុវណ្ណ*

*ប្រភពច្បាប់៖ មាត្រា ២ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ២ និង ២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣១ នៃកថាខណ្ឌទី ២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ២ ចំណុច (ក) ឬ (A) នៃគោលការណ៍ យ៉ូកយ៉ាកាតា។*

# សិទ្ធិរស់រានមានជីវិត បូរណភាពបុគ្គល និងប្រឆាំងទាសភាព

អ្នកមានសិទ្ធិរស់រានមានជីវិត សិទ្ធិបូរណភាពបុគ្គល ហើយនិងសិទ្ធិប្រឆាំងនឹងទាស ភាព។ សិទ្ធិទាំងអស់នោះមានន័យថា៖

- គ្មាននរណាម្នាក់ គំរាមកំហែងជីវិតរបស់អ្នក ដោយផ្អែកលើមូលដ្ឋាននិន្នាការភេទនិងអត្តសញ្ញាណយេនឌ័រនោះទេ។ (ជាពិសេសទោសប្រហារជីវិតត្រូវបានហាមឃាត់ជាដាច់ខាតនៅក្នុងប្រទេសកម្ពុជា)។
- សិទ្ធិបូរណភាពបុគ្គលរបស់អ្នក នឹងមិនត្រូវបានគំរាមកំហែងបើទោះបីជាក្នុងករណីអ្នកត្រូវបានដកហូតសេរីភាពក៏ដោយ។
- អ្នកមិនត្រូវបានគេដាក់ទណ្ឌកម្ម ឬ ព្យាបាទដោយប្រើមធ្យោបាយ ដ៏ឃោរឃៅឬអមនុស្សធម៌ណាមួយ ឬ ធ្វើទារុណកម្មនោះទេ។
- គ្មាននរណាម្នាក់ អាចចាត់ទុកអ្នកជាទាសករ ឬ ធ្វើការជួញដូរខុសច្បាប់បានឡើយ។

*« ខ្ញុំកើតមកជាស្រីម្នាក់ ប៉ុន្តែខ្ញុំបានប្តូរឈ្មោះឪរពីស្រីទៅប្រុស។ ដប់ឆ្នាំមុន នៅពេលគ្រួសាររបស់ខ្ញុំបានដឹងថាខ្ញុំស្រឡាញ់មនុស្សស្រី ពួកគាត់មិនព្រមទទួលស្គាល់ ហើយបានបង្ខំឲ្យខ្ញុំរៀបការជាមួយបុរសម្នាក់។ ម្តាយរបស់ខ្ញុំបានចាក់សោរខ្ញុំឃុំនៅក្នុងបន្ទប់រហូតដល់ថ្ងៃរៀបការ។ ស្ថានភាពនេះបានធ្វើឲ្យខ្ញុំគិតចង់សម្លាប់ខ្លួន ដែលវាជាជម្រើសតែមួយគត់។ ថ្វីបើខ្ញុំសម្រេចចិត្តរត់គេចចេញពីគ្រួសារ និងសហគមន៍របស់ខ្ញុំបន្ទាប់ពីបានរៀបការរួចមក តែនៅពេលនោះខ្ញុំមិនបានដឹងអ្វីទាំងអស់ពីសិទ្ធិរបស់ខ្ញុំទេ។ ខ្ញុំក៏មិនបានដឹងដែរថា ការបង្ខំឲ្យរៀបការគឺត្រូវបានហាមឃាត់ដោយច្បាប់។»*

......................................................................................................... *ភក្តី*

*ប្រភពច្បាប់៖ មាត្រា៣ និងមាត្រា ៤ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ។ មាត្រា ៦ មាត្រា៧ និង មាត្រា ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៣២ និង មាត្រា ៣៨នៃរដ្ឋធម្មនុញ្ញរាជាណាចក្រកម្ពុជានិងគោលការណ៍៤នៃគោលការណ៍យ៉កយ៉ាកាតា។*

# សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់និងសិទ្ធិទទួលបានមធ្យោបាយដោះស្រាយដោយមានប្រសិទ្ធិភាព

អ្នកមានសិទ្ធិស្មើភាពគ្នានៅចំពោះមុខច្បាប់។ អ្នកក៏មានសិទ្ធិទទួលបានមធ្យោបាយដោះស្រាយមានប្រសិទ្ធិភាពផងដែរ។ សិទ្ធិទាំងនោះមានន័យថាៈ

- ច្បាប់អនុវត្តលើបុគ្គលគ្រប់រូប តម្រូវតាមមធ្យោបាយស្មើគ្នាមួយ ហើយក៏គ្មាននរណាម្នាក់នៅពីលើច្បាប់ឡើយ ឬ ត្រូវបានរើសអើង ដោយឈរលើមូលដ្ឋានចរិតលក្ខណៈខុសៗគ្នាដូចជាភេទរបស់អ្នកដែរ។ ការផ្តែកទៅលើបរិបទភេទ គឺគ្របដណ្តប់លើនិន្នា ការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នក។
- អ្នកមានសិទ្ធិ ដើម្បីទទួលបានការការពារ ពីច្បាប់ប្រឆាំងនឹង ការរើសអើង។ ច្បាប់នោះ គួរតែហាមឃាត់ ការរើសអើងណាដែលឈរលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។
- ប្រសិនបើសិទ្ធិណាមួយរបស់អ្នកត្រូវបានគេបំពាន ទោះជាផ្អែក ឬ មិនផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ អ្នកមានសិទ្ធិដើម្បីដាក់ពាក្យប្តឹង ឬ ទាមទារសំណងនៅចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច។
- ការដោះស្រាយ ទៅលើពាក្យបណ្តឹង និងការអះអាងសម្រាប់សំណងការខូចខាតទាំងឡាយគឺជាការទទួលខុសត្រូវរបស់ប្រព័ន្ធយុត្តិធម៌។

សិទ្ធិទទួលបានភាពស្មើគ្នានៅចំពោះមុខច្បាប់គឺជាឆ័ត្រមួយ មានន័យថាសិទ្ធិនេះឆ្លើយតបទៅសិទ្ធិដទៃទៀតជាច្រើន។

« ថ្ងៃមួយខ្ញុំបានចេញទៅឆ្ងាយពីខ្ទមដែលខ្ញុំ និងប្រពន្ធរបស់ខ្ញុំរស់នៅ។ បន្ទាប់មកមាន ទាហានម្នាក់បានមកបង្ខំប្រពន្ធរបស់ខ្ញុំរួមភេទជាមួយគាត់រហូតធ្វើនាងមានផ្ទៃពោះ។ គាត់បានបង្ខំខ្ញុំឲ្យប្រពន្ធទៅគាត់។វាបានបង្ហាញឲ្យឃើញថាទោះបីជា យើងមានទំនាក់ទំនងស្នេហា ដ៏ល្អជាមួយគ្នា មនុស្សនៅតែរើសអើងពួកយើងព្យាយាមបំបែកយើងចេញពីគ្នានិងបដិសេធសិទ្ធិស្មើភាពគ្នា និងសិទ្ធិមិនទទួលបានការរើសអើង។ »

.......................................................................................... ភក្តី

*ប្រភពច្បាប់៖ មាត្រា ៧ និងមាត្រា ៨ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ។ មាត្រា៩ មាត្រា ១៤ និង ១៦ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ។ មាត្រា ៣៨ និងមាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ៣ និង ២៨នៃគោលការណ៍យ៉ូកយ៉ាកាតា។*

# សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងត្រូវបានសន្មត់ថាគ្មានទោស

អ្នកមានសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អ្នកក៏មានសិទ្ធិត្រូវបានសន្មត់ថាគ្មានទោស។ សិទ្ធិទាំងនោះមានន័យថា៖

- នៅក្នុងហេតុការណ៍ ដែលអ្នកត្រូវបានគេចោទពីបទព្រហ្មទណ្ឌ អ្នកមានសិទ្ធិស្មើគ្នាពេញលេញ ក្នុងការស្នើសុំឲ្យ តុលាការពិនិត្យរឿង ក្តីរបស់ខ្លួនជាសាធារណៈ ដោយសមធម៌ ឯករាជ្យ និងមិនលំអៀងដែលបង្កើតដោយច្បាប់។
- នៅក្នុងការចោទប្រកាន់មួយ អ្នកត្រូវតែមានប្រយោជន៍ ទៅលើវិមតិសង្ស័យណាមួយ និងសន្មត់ថាគ្មានទោសរហូតដល់ពិរុទ្ធភាពត្រូវបានរកឃើញដោយសេចក្តីសម្រេចរបស់តុលាការ។
- ដោយមិនគិតពីនិន្នាការផ្លូវភេទ និងអត្តសញ្ញាណរបស់អ្នកអ្នកត្រូវតែមានសិទ្ធិដើម្បីការពារខ្លួនតាមរយៈប្រព័ន្ធយុត្តិធម៌។

« ខ្ញុំគឺជាអ្នកប្តូរយេនឌ័រពីស្រីទៅប្រុស។ នៅពេលឪពុកម្តាយមិត្តស្រីរបស់ខ្ញុំបានដឹង ពីទំនាក់ទំនងរបស់ពួកយើង គាត់បានប្តឹងប៉ូលិសឲ្យមកចាប់ខ្ញុំ ដោយចោទប្រកាន់ខ្ញុំពីបទជួញដូរមនុស្ស។ ទោះបីជាខ្ញុំបានប្រាប់ប៉ូលិសថា ពួកយើងទាំងពីរ ស្រឡាញ់គ្នាដោយពិតប្រាកដ ប៉ុន្តែពួកគាត់ថាខ្ញុំកំពុងកុហក។ ពួកគាត់បានបង្ខំឲ្យគ្រួសារខ្ញុំបង់ប្រាក់៨លានរៀល ប្រសិនបើគ្រួសារខ្ញុំចង់នាំខ្ញុំត្រឡប់ទៅផ្ទះវិញ។ ពួកយើងមិនមានលទ្ធភាពបង់លុយទាំងនេះទ្បើយ។ ហេតុដូច្នេះហើយទើបខ្ញុំបានជាប់ពន្ធនាគារជាច្រើនខែ។ ខ្ញុំបានទទួលជំនួយផ្នែកមេធាវីហូតដល់ខ្ញុំឈ្នះក្តីនេះ។ »

.............................................................................................សាវ៉ាន់

ប្រភពច្បាប់៖ មាត្រា ១១ និងមាត្រា ១២ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ៤ និង ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ៨ នៃគោលការណ៍យ៉កយ៉ាកាតា។

# សិទ្ធិប្រឆាំងនឹងការឃុំខ្លួនដោយបំពាន

អ្នកមានសិទ្ធិប្រឆាំងនឹងការឃុំខ្លួនដោយបំពាន។ សិទ្ធិទាំងនោះមានន័យថាៈ

- អ្នកមិនត្រូវបានចាប់ខ្លួន ឃុំខ្លួន ឬ និរទេសខ្លួនដោយបំពានឡើយ។
- ការចាប់ខ្លួន ឬ ឃុំខ្លួនដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ទោះបីជាលទ្ធផលនៃសេចក្តីសម្រេចរបស់តុលាការក៏ដោយ វានឹងត្រូវបានចាត់ទុកថាជាការបំពាន បើមិនដូច្នោះទេគឺខុសច្បាប់។
- បុគ្គលគ្រប់រូបដែលត្រូវបានចាប់ខ្លួន ត្រូវបានប្រាប់ពីមូលហេតុនៃការចាប់ខ្លួននេះដោយមិនផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

« ខ្ញុំគឺជាអ្នកប្តូរយេនឌ័រពីប្រុសទៅស្រី ហើយខ្ញុំស្រឡាញ់បុរស។ ពេលយប់មួយនោះ ខ្ញុំបានចេញទៅដើរលេងនៅសួនច្បារសាធារណៈ។ មានប៉ូលិសមួយក្រុមបានមកចាប់ខ្លួនខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំ។ ពួកគេបានគំរាមយើងឲ្យចូលទៅ ក្នុងឡានរបស់ពួកគេ បើមិនដូច្នោះពួកគេនឹងបាញ់យើង។ ទាល់តែទៅដល់ប៉ុស្តិ៍ប៉ូលិសទើបគេប្រាប់ថា ពួកគេចាប់យើង ពីព្រោះឥរិយាបថរបស់ពួកយើងធ្វើឲ្យប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ហើយថាពួកយើងជាក្រុមអ្នកជួញដូរផ្លូវភេទ។ ប៉ុន្តែពួកយើងមិនបានធ្វើដូច្នោះទេប៉ូលិសទាំងនោះមិនបានចាប់អ្នកផ្សេងទៀតទេ គេចាប់តែពួកយើងព្រោះយើងខុសពីគេ។ ពួកគេឃុំយើង១៦ម៉ោងទោះបីយើងមិនបានប្រព្រឹត្តបទល្មើសឧក្រិដ្ឋក៏ដោយ។ ហើយបន្ទាប់មក ទើបគេដោះលែងយើង។ »

..........................................................................................ស្រីម៉ៅ

*ប្រភពច្បាប់៖ មាត្រា ៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ៣៩ មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ៧ នៃគោលការណ៍យ៉កយ៉ាកាតា។*

# សិទ្ធិសេរីភាពក្នុងការធ្វើដំណើរ

អ្នកមានសេរីភាពក្នុងការធ្វើដំណើរ។ សិទ្ធិទាំងនោះមានន័យថា៖

- អ្នកមានសិទ្ធិធ្វើដំណើរទៅសួនច្បារ និងទីធ្លាសាធារណៈទាំងអស់ដោយគ្មានការរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ អត្តសញ្ញាណយេនឌ័ររបស់អ្នកនោះទេ។
- អ្នកមានសិទ្ធិ ធ្វើដំណើរនៅក្នុងទឹកដី នៃប្រទេសរបស់អ្នក ដោយមិនគិតលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នក។
- អ្នកមានសិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផងដែរ។ ហើយអ្នកមានសិទ្ធិត្រឡប់មកប្រទេសរបស់អ្នកវិញដោយសេរី មិនផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រទេ។

*« ពេលខ្លះ ខ្ញុំចូលចិត្តស្លៀកពាក់ខោអាវស្រីនៅផ្ទះ តែម្តាយរបស់ខ្ញុំតែងតែវាយខ្ញុំនៅពេលដែលខ្ញុំធ្វើដូចនេះ។ ខ្ញុំក៏ត្រូវស្លៀកពាក់ខោអាវបុរស ពេលនៅទីសាធារណៈដូចគ្នាដែរ ដើម្បីជៀសផុតពីការប្រឈមមុខនឹងផលវិបាកជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចដែលរើសអើងមនុស្សដូចខ្ញុំ។ »*

*........................................................................................... ផល្លី*

*ប្រភពច្បាប់៖ មាត្រា ១៣ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ១២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍យ៉កយ៉ាកាតា*

# សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

អ្នកមានសេរីភាពនៅក្នុងការបញ្ចេញមតិ។ សេរីភាពនេះមានន័យថា៖

- អ្នកមានសិទ្ធិសេរីភាព ក្នុងការបញ្ចេញមតិយោបល់ ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកនោះទេ ដរាបណាវាមិនមានការប៉ះពាល់សិទ្ធិឯកជនរបស់អ្នកដទៃ បទបញ្ញា និងសន្តិសុខសាធារណៈ។
- អ្នកមានសេរីភាពដើម្បីបង្ហាញនូវអត្តសញ្ញាណ ឬ បុគ្គលិកលក្ខណៈរបស់អ្នកតាម រយៈការនិយាយស្តី អាកប្បកិរិយា ឥរិយាបថ សម្លៀកបំពាក់ ជម្រើសនៃការដាក់ឈ្មោះ ឬ ធម្មោបាយដទៃទៀត។
- អ្នកមានសិទ្ធិស្វែករក និងទទួលបានព័ត៌មានសំខាន់ៗគ្រប់ប្រភេទ ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។
- សេរីភាពនៃការបញ្ចេញមតិរបស់អ្នក រួមបញ្ចូលទាំងសេរីភាពនៃការផ្សព្វផ្សាយ និងចូលរួមប្រជុំដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

« ខ្ញុំជាបុរសស្រឡាញ់បុរស។ ខ្ញុំធ្លាប់ចាកចេញពីផ្ទះដោយសារគ្រួសាររបស់ខ្ញុំចង់ឲ្យខ្ញុំរៀបការជាមួយនារីម្នាក់ ហើយពួកគាត់តែងតែស្តីចំអកឡកឲ្យខ្ញុំ។ កាលខ្ញុំនៅតូច ឪពុកម្តាយរបស់ខ្ញុំធ្លាប់ហៅខ្ញុំថាខ្ទើយ ហើយបងប្រុស និងឪពុករបស់ខ្ញុំនៅតែហៅបែបនេះ ទោះបីជាពួកគាត់ដឹងថាខ្ញុំមិនចូលចិត្តក៏ដោយ។ ប៉ុន្តែពេលនេះខ្ញុំបានចាកចេញពីពួកគាត់ហើយ ខ្ញុំមិនចង់បង្ខំខ្លួនឯងត្រូវតាំងខ្លួនជាបុរសម្នាក់នោះទេ។ »

............................................................................................................ផល្លី

*ប្រភពច្បាប់៖ មាត្រា ១៩ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ១៨ និង ១៩ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ១៩ នៃគោលការណ៍យ៉កយ៉ាកាតា។*

# សិទ្ធិទទួលបានសេវាសុខភាព និងសន្តិសុខសង្គម

អ្នកមានសិទ្ធិទទួលបានសុខភាពល្អ ហើយអ្នកក៏មានសិទ្ធិទទួលបានសន្តិសុខសង្គមផងដែរ។ សិទ្ធិទាំងនោះមានន័យថាៈ

- អ្នកមានសិទ្ធិទទួលបាននូវ ការពិនិត្យព្យាបាលសុខភាព និងយ៉ាងហោចណាស់មានកម្រិតនៃការរស់នៅសមរម្យដែលអាចទទួលយកបាន។
- អ្នកមានសិទ្ធិទទួលបានសេវាសុខភាព ដ៏ប្រសើរបំផុតតាម ដែលអាចធ្វើទៅបាន ទាំងសុខភាពផ្នែករាងកាយ បន្តពូជ ផ្លូវភេទ និងផ្លូវចិត្ត ដោយគ្មានការរើសអើងប្រឆាំងទៅនឹងមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។
- រដ្ឋគួរតែយកចិត្តទុកដាក់អំពីការការពារជំងឺ និងការប្រើប្រាស់ថ្នាំព្យាបាលដល់ប្រជាពលរដ្ឋគ្រប់រូប។

*« ឆ្នាំមុនតាមរយៈការណែនាំរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ខ្ញុំបានទៅមន្ទីរពេទ្យរដ្ឋមួយ ដើម្បីទទួល ការពិនិត្យសុខភាព។ បន្ទាប់ពីរង់ចាំអស់រយៈពេល ២ម៉ោង ខ្ញុំបានដឹងថាគ្រូពេទ្យបានទទួលអ្នកជំងឺដែលមកក្រោយខ្ញុំ ដែលពួកគាត់ក៏បានមកទទួលសេវាពិនិត្យសុខភាពដែរ។ ទោះបីខ្ញុំព្យាយាមធ្វើល្អ រួសរាយរាក់ទាក់ដាក់គាត់ គាត់នៅតែបដិសេធមិនពិនិត្យខ្ញុំ។ វាធ្វើឲ្យខ្ញុំមានអារម្មណ៍អន់ចិត្ត យ៉ាងខ្លាំង ដែលត្រូវទទួលការរើសអើង ដោយសារនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ដែលផ្ទុយពីភេទកំណើតរបស់ខ្ញុំ។ ខ្ញុំគិតថា មនុស្សគ្រប់រូបគួរតែទទួលបានសេវាសុខភាពស្មើៗគ្នា ជាពិសេសគ្រូពេទ្យមិនគួររើសអើងប្រជាពលរដ្ឋនោះទេ។ »*

........................................................................................................*សុភ័ក្ត្រ*

*ប្រភពច្បាប់៖ មាត្រា ២៣ និង ២៥ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា មាត្រា ៩ និង ១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។ មាត្រា៣៦ និងមាត្រា ៧២ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ៥ ១២ និង១៧ នៃគោលការណ៍យ៉កយ៉ាកាតា។*

# សិទ្ធិមានការងារ

អ្នកមានសិទ្ធិធ្វើការងារ។ សិទ្ធិនេះមានន័យថា៖

- អ្នកគួរតែចូលរួមទទួលបានសិទ្ធិដើម្បីជ្រើសរើសការងារណាមួយ ដោយយោងទៅតាមសមត្ថភាពរបស់អ្នក មិនមែនផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នកឡើយ។ អ្នកគួរតែទទួលបានប្រាក់បៀវត្សចំពោះមុខតំណែង និងតួនាទីដូចគ្នានឹងជនដទៃទៀតដែរ។
- អ្នកមានសិទ្ធិបង្កើត និងចូលរួមការងារសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ដោយមិនគិតពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់អ្នក។
- អ្នកមានសិទ្ធិទទួលបានលាភសក្ការៈ ពីការងារដោយ មិនមានការរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

*« មុនពេលខ្ញុំមកធ្វើការនៅកន្លែងបច្ចុប្បន្ននេះ ខ្ញុំត្រូវបានគេរើសអើងនៅកន្លែងហ្វឹកហាត់ការងារ (ចុះកម្មសិក្សា) ដោយសារតែនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំ។ នៅពេលដែលអតីតប្រធានរបស់ខ្ញុំដឹងថា ខ្ញុំគឺជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស គាត់បានលុបចោលកិច្ចសន្យាការងារកម្មសិក្សារបស់ខ្ញុំ។ ដូច្នេះទើបខ្ញុំចាប់ ផ្តើមធ្វើការឲ្យអង្គការអ្នកស្រឡាញ់ភេទដូចគ្នា។ ខ្ញុំត្រូវចូលរួមផ្សព្វផ្សាយពីសិទ្ធិរបស់ខ្ញុំ ក៏ដូចជាសិទ្ធិរបស់ពួកយើង។ »*

................................................................................................ *សៀកឡាយ*

*ប្រភពច្បាប់៖ មាត្រា ២៣ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស។ មាត្រា ៧ និង ៨ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។មាត្រា ៣៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា និងគោលការណ៍ ១២ នៃគោលការណ៍យ៉កយ៉ាកាតា។*

# សិទ្ធិទទួលបានការអប់រំ

អ្នកមានសិទ្ធិទទួលបានការអប់រំ។ សិទ្ធិទាំងនោះមាន៖

- អ្នកមានសិទ្ធិទទួលបានការអប់រំដោយមិនមានការរើសអើង។
- ការអប់រំថ្នាក់បឋមគួរតែមិនគិតថ្លៃ និងអាចទទួលបានគ្រប់កម្រិតទាំងអស់។ កម្រិតឧត្តមសិក្សាគួរតែទទួលបានតាមដែលអាចធ្វើទៅបាន និងមិនមានការរើសអើងដោយផ្អែកលើមូលដ្ឋាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។
- រដ្ឋគួរតែការពារ និងជំរុញសិទ្ធិរបស់អ្នកឲ្យទទួលបានការអប់រំដែលមានគុណភាពនៅគ្រប់កម្រិត។
- ការអប់រំបច្ចេកទេស និងផ្នែកវិជ្ជាជីវៈគួរតែមានជាទូទៅ។

*« ខ្ញុំគឺជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅជាបុរស និងជានិស្សិតសាកលវិទ្យាល័យម្នាក់។ នៅពេលដែលខ្ញុំរៀននៅវិទ្យាល័យ មិត្តភក្តិស្រីៗរបស់ខ្ញុំបានបង្ខំឲ្យខ្ញុំធ្វើជាស្រីម្នាក់ពិតប្រាកដ ដើម្បីអាចរៀបការជាមួយបុរសម្នាក់ មានកូន និងបំពេញបំណងប្រាថ្នា របស់ឳពុកម្តាយ ទុកជាការតបស្នងគុណ ទៅពួកគាត់។ ការស្លៀកឯកសណ្ឋាននារីធ្វើឲ្យខ្ញុំមានអារម្មណ៍មិនល្អនោះទេ។ ហេតុដូច្នេះហើយ ខ្ញុំបានលើកឡើងអំពីរឿងនេះ ជម្រាបដល់ប្រធាន ដឺប៉ាត់ម៉ង់ និងព្រឹទ្ធបុរសនៃសាកលវិទ្យាល័យ ដែលពួកគាត់ទាំងពីរនាក់បានយល់ព្រមឲ្យខ្ញុំអាចស្លៀកពាក់ឯកសណ្ឋានបុរសបាន។ »*

.................................................................................... *សៀកឡាយ*

ប្រភព៖


- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ ដែលមាននៅ http://cambodia.ohchr.org/klc_pages/KLC_files/section_001/section_01_01_ENG.pdf
- UNDP និង USAID ក្រុមអ្នកស្រទ្បាញ់ភេទដូចគ្នានៅអាស៊ី។ របាយការណ៍ប្រទេស កម្ពុជា ២០១៤ ដែលមាននៅ http://www.usaid.gov/sites/default/files/documents/1861/rbap-hhd-2014-blia-cambodia-country-report.pdf
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ១៩៤៨ ដែលមាននៅ http://www.un.org/Overview/rights.html
- គោលការណ៍យ៉កយ៉ាកកាតា ២០០៧ ដែលមាននៅ http://www.yogyakartaprinciples.org/
- Chbab.net កម្មវិធីដែលមានលក្ខណៈអន្តរកម្ម និងច្នៃប្រឌិតដើម្បីប្រមូលទិន្នន័យច្បាប់ ការអភិវឌ្ឍន៍សហគមន៍ទៅលើបញ្ហាយុត្តិធម៌ ក៏ដូចជាការកាត់
- បន្ថយគំលាតធនធានច្បាប់ និងការទទួលបានព័ត៌មាន ដែលមាននៅ http://kh.chbab.net/
- គេហទំព័រអង្គការសហគមន៍ឥន្ទធនូកម្ពុជា www.rockcambodia.org និងទំព័រ ហ្វេសប៊ុក facebook.com/RoCKHMERLGBT2009
- Sam Killerman, សៀវភៅណែនាំអំពីការគាំទ្រយុត្តិធម៌សង្គម។ មគ្គុទ្ទេសក៏ស្វែងយល់អំពីយេនឌ័រ ២០១៣ ដែលមាននៅ http://itspronouncedmetrosexual.com/

# កម្រងមាត្រានៃច្បាប់ជាតិយោងទៅតាមសិទ្ធិនីមួយៗ

## ១. សិទ្ធិមិនទទួលការរើសអើង

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣១:

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយ ទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នា ចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយដើមកំណើតជាតិឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រ២:

១. រដ្ឋភាគីនៃកតិកាសញ្ញានេះសន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតនៅក្រោមដែនសមត្ថកិច្ច របស់ខ្លួននូវសិទ្ធិដែលទទួលស្គាល់កតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយមានដូចជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀតឡើយ។

២. បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទប្បញ្ញត្តិទាំងឡាយ នៃកតិកាសញ្ញានេះដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀតដែលចាំបាច់ដើម្បីធ្វើឱ្យសម្រេចបាននូវសិទ្ធិទាំងឡាយដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ

៣. រដ្ឋភាគីនៃកតិកាសញ្ញានេះសន្យា៖

(ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិ និងសេរីភាពរបស់ខ្លួនដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះ មានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តិដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។

(ខ) ធានាថាជនណា ដែលប្តឹងឱ្យមានការដោះស្រាយ បែបនេះត្រូវមានសិទ្ធិឱ្យអាជ្ញាធរសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឱ្យខ្លួនដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។

(គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ចត្រូវអនុវត្ត ឱ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។

គ. គោលការណ៍យ៉កយ៉ាកាតា

គោលការណ៍២(ក)៖ រដ្ឋមានកាតព្វកិច្ចត្រូវដាក់បញ្ចូលគោលការណ៍សមភាព និងការមិនរើសអើងដែលឈរលើមូដ្ឋាននៃនិន្នាការភេទ ឬ អត្តសញ្ញាណយេនឌ័រក្នុងរដ្ឋធម្មនុញ្ញ ឬ ច្បាប់សមស្របផ្សេងទៀតរបស់ខ្លួន ប្រសិនណាមិនទាន់បានដាក់បញ្ចូលទេនោះ ដែលអាចធ្វើឡើងតាមរយៈវិសោធនកម្ម និងបំណកស្រាយហើយត្រូវធានាសម្រេចឱ្យបាននូវគោលការណ៍នេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

ឃ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ២

មនុស្សម្នាក់ៗ អាចប្រើប្រាស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការប្រកាន់បែងចែកបែបណាមួយ មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនាមតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬ សង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។ លើសពីនេះ បុគ្គលគ្រប់រូបមិនត្រូវធ្វើការប្រកាន់ បែងចែកណាមួយ ដោយសំអាងទៅលើឋានៈ ខាងនយោបាយ ខាងដែនសមត្ថកិច្ច ឬ ខាងអន្តរជាតិរបស់ប្រទេស

ឬ ដែនដីដែលបុគ្គលណាម្នាក់រស់នៅ ទោះបីជាប្រទេស ឬដែនដីនោះឯករាជ្យក្ដី ស្ថិតក្រោមអាណាព្យាបាលក្ដី ឬគ្មានស្វ័យគ្រប់គ្រងក្ដី ឬស្ថិតក្រោមការដាក់កម្រិតផ្សេងទៀតណាមួយដល់អធិបតេយ្យភាពក្ដី។

## ២. សិទ្ធិរស់រានមានជីវិត

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣២:

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន។ ទោសប្រហារជីវិតមិនត្រូវអោយមានឡើយ។

មាត្រា៣៨:

ច្បាប់ហាមឃាត់មិនអោយ មានការរំលោភបំពាន លើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិតកិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការចោទប្រកាន់ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

ការបង្ខិតបង្ខំការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារត្រូវហាមឃាត់មិនអោយធ្វើឡើយ។

អ្នកដៃដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើង ពីការបង្ខិតបង្ខំតាមផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដីមិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យត្រូវបានជា ប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ខ. កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា៧

គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬប្រព្រឹត្ដិ ឬទណ្ឌកម្ម ដែលឃោរឃៅ

អមនុស្សធម៌ ឬធ្វើឱ្យថោកទាបឡើយ។ ជាពិសេស ហាមយកជនណាម្នាក់ មកធ្វើការពិសោធន៍ខាងវេជ្ជសាស្ត្រ ឬ វិទ្យាសាស្ត្រ ដោយគ្មានការយល់ព្រមដោយសេរីពីសាមីខ្លួនឡើយ។

មាត្រា៨

១. គ្មានជនណាម្នាក់ ត្រូវជាប់ក្នុងទាសភាពឡើយ។ ទាសភាព និងទាសពាណិជ្ជកម្ម តាមគ្រប់ទម្រង់ទាំងអស់ ត្រូវហាមឃាត់។

២. គ្មានជនណាម្នាក់ត្រូវជាប់ក្នុងភាពជាខ្ញុំបម្រើដាច់ថ្លៃឡើយ។

៣.(ក) គ្មានជនណាម្នាក់ តម្រូវឱ្យធ្វើការដោយបង្ខំ ឬខានមិនបានឡើយ។

(ខ) កថាខណ្ឌ៣(ក) មិនត្រូវយកមកបកស្រាយថា ហាមឃាត់ការអនុវត្តន៍ទោសឱ្យធ្វើការដោយបង្ខំ ស្របតាមការវិនិច្ឆ័យទោស ដោយតុលាការមានសមត្ថកិច្ចក្នុងប្រទេស ដែលបទឧក្រិដ្ឋខ្លះ អាចមានទោសជាប់គុកឱ្យធ្វើការដោយបង្ខំ។

(គ) បំណងនៃកថាខណ្ឌនេះ ពាក្យថា "ការងារដោយបង្ខំ ឬ ដោយខានមិនបាន" មិនត្រូវរាប់បញ្ចូលៈ

(i) ការងារ ឬសេវាដែលគ្មានចែងក្នុងអនុកថាខណ្ឌ(ខ) និងដែលតម្រូវជាធម្មតា ចំពោះជនជាប់ឃុំ តាមបទបញ្ជាស្របច្បាប់របស់តុលាការ ឬ ចំពោះជនដែលតុលាការសម្រេចដោះលែងឱ្យមានសេរីភាព ដោយមានលក្ខខណ្ឌ។

(ii) សេវាដែលមានលក្ខណៈយោធា និងកិច្ចការបំរើជាតិដែលតម្រូវតាមច្បាប់សម្រាប់អ្នកប្រឆាំងសង្គ្រាម នៅក្នុងប្រទេសដែលទទួលស្គាល់សិទ្ធិប្រឆាំងសង្គ្រាម។

(iii) សេវាដែលតម្រូវក្នុងករណីមានអាសន្ន ឬគ្រោះមហន្តរាយ ដែលគំរាមកំហែងដល់អាយុជីវិត និងសុខុមាលសហគមន៍។

(iv) ការងារ ឬសេវា ដែលជាផ្នែកនៃកាតព្វកិច្ចធម្មតា របស់ប្រជាពលរដ្ឋ។

គ. គោលការណ៍យ៉កយ៉ាកាតា

គោលការណ៍៤

បុគ្គលគ្រប់រូប មានសិទ្ធិរស់រានមានជីវិត។ គ្មានបុគ្គលណាមួយអាចបំពានយក

ជីវិតនរណាម្នាក់បានឡើយ នេះរាប់ទាំងការសម្លាងលើការពិចារណាអំពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ។ ការដាក់ទោសប្រហារជីវិតមិនត្រូវធ្វើឡើង ដោយឈរលើមូលដ្ឋានទាក់ទងនឹង សកម្មភាពផ្លូវភេទ ដែលត្រូវបានព្រមព្រៀងប្រព្រឹត្តិដោយបុគ្គល ដែលគ្រប់អាយុអនុញ្ញាត ឬលើមូលដ្ឋានទាក់ទងនឹងនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ។

រដ្ឋមានកាតព្វកិច្ចត្រូវ៖

ក. លុបចោលរាល់ទម្រង់ទាំងអស់នៃបទឧក្រិដ្ឋ ដែលមានគោលបំណង ឬ ឥទ្ធិពលហាមឃាត់សកម្មភាពផ្លូវភេទព្រមព្រៀងប្រព្រឹត្តិដោ យបុគ្គលគ្រប់អាយុ ហើយដរាបណាបញ្ញត្តិនេះនៅជាធរមានមិនត្រូវដាក់ទោសប្រហាជីវិតចំពោះបុគ្គល ដែលត្រូវបានកាត់ឱ្យជាប់ទោសពីបទឧក្រិដ្ឋទាំងនោះឡើយ។

ខ. លើកលែងទោសប្រហារជីវិត និងសម្រាលទោសអ្នករងចាំការកាត់ទោសប្រហារជីវិតក្នុងពេលថ្មីៗ ចំពោះឧក្រិដ្ឋកម្ម ដែលទាក់ទងនឹងការយល់ព្រមឱ្យមានសកម្មភាពផ្លូវភេទ ក្នុងចំណោមមនុស្សដែលគ្រប់អាយុអនុញ្ញាត។

គ. បញ្ឈប់រាល់ការឧត្តម្ភ ឬការអនុញ្ញាតឱ្យធ្វើអំពើខុសឆ្គងរបស់រដ្ឋទៅលើការរស់នៅ របស់បុគ្គលិកទាំងឡាយ ដោយសម្អាងលើ និន្នាការភេទ និង អត្តសញ្ញាណយេនឌ័រ និងត្រូវធានាថា រាល់ការវាយប្រហារជីវិតទាំងអស់ ទោះជាធ្វើឡើងដោយមន្ត្រីរដ្ឋាភិបាល បុគ្គល ឬក្រុមណាមួយក៏ដោយ ត្រូវធ្វើការសើបអង្កេតយ៉ាងតឹងរឹង ហើយខណៈណាភស្តុតាងពិតប្រាកដត្រូវបានរកឃើញ មនុស្សទាំងនោះ និងត្រូវបានផ្តន្ទាទោស និងសួរចម្លើយ និងកាត់ទោសដ៏ត្រឹមត្រូវ។

ឃ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ៣

បុគ្គលម្នាក់ៗ ត្រូវមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។

មាត្រា ៤

គ្មានជនណាម្នាក់ត្រូវជាប់ក្នុងភាពជាទាសករ ឬ ក្នុងភាពជាអ្នកបម្រើគេឡើយ ហើយការជួញដូរទាសករក្នុងទម្រង់យ៉ាងណាក៏ដោយត្រូវហាមឃាត់។

## ៣. សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងនន្ទូលបានមធ្យោបាយ

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣៨:

ច្បាប់ហាមឃាត់ មិនអោយមានការរំលោភបំពាន លើរូបរាងកាយបុគ្គលណាមួយឡើយ។ ច្បាប់ការពារជីវិតកិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

ការចោទប្រកាន់ ការចាប់ខ្លួនការឃាត់ខ្លួន ឬការឃុំខ្លួនជនណាមួយ និងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់។

ការបង្ខិតបង្ខំការធ្វើបាប លើរូបរាងកាយ ឬ ប្រព្រឹត្តិកម្មណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារត្រូវហាមឃាត់មិនអោយធ្វើឡើយ។

អ្នកដែដល់ អ្នករួមប្រព្រឹត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់។ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ។ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។

ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ។ ជនគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

មាត្រា៣៩

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬ ប្តឹងទារសំណងជួសជុលខូចខាតដែលបណ្តាលមកពី អំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

ខ. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា១៤

១. ជនគ្រប់រូបត្រូវមានភាពស្មើគ្នាចំពោះមុខតុលាការ និងសាលាជំរះក្តី។ ជនគ្រប់រូប ត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ដែលប ង្កើ តឡើងដោយច្បាប់ ជំនុំជំរះរឿក្តីរបស់ខ្លួន ដោយសមធម៌ និងជាសា ធារណៈ

ដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួន ក្នុងវិស័យព្រហ្មទណ្ឌ ឬ លើសិទ្ធិ និងករណីកិច្ច ក្នុងវិស័យរដ្ឋប្បវេណី។ សារព័ត៌មាន និងសាធារណៈជន អាចមិនឱ្យចូលរួមទាំងស្រុង ឬផ្នែកមួយនៃសវនាការ សម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់ល្អ សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិក្នុងសង្គមប្រជាធិបតេយ្យ ឬ នៅពេលផលប្រយោជន៍ នៃជីវិតឯកជនរបស់គូភាគី តម្រូវឱ្យធ្វើដូច្នេះ ឬក្នុងកម្រិតដែលចាំបាច់បំផុត តាមការយល់ឃើញរបស់តុលាការ ក្នុងស្ថានភាពពិសេស ដែលថា ការធ្វើជាសាធារណៈនឹងនាំឱ្យខូចដល់ផលប្រយោជន៍យុត្តិធម៌។ ប៉ុន្តែការចេញសាលក្រមទាំងអស់ អំពីរឿងព្រហ្មទណ្ឌ ឬរដ្ឋប្បវេណី ត្រូវប្រកាសជាសាធារណៈ លើកលែងតែផលប្រយោជន៍អនីតិជន តម្រូវផ្សេងពីនេះ ឬរឿងក្តីអំពីទំនាស់គ្រួសារ ឬអាណាព្យាបាលរបស់កុមារ។

២. ជនដែលជាប់ចោទពីបទព្រហ្មទណ្ឌ ត្រូវបានសន្មត់ជាមុនថា ជាជនគ្មានទោស រហូតដល់ពិរុទ្ធភាពរបស់ខ្លួន ត្រូវបានកំណត់ស្របតាមច្បាប់។

៣. ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបានការធានាជាអប្បបរមា ដោយស្មើភាពគ្នាយ៉ាងពេញលេញ ដូចខាងក្រោម៖

(ក) ត្រូវបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន ជាភាសាដែលជននោះចេះ។

(ខ) ត្រូវមានពេលវេលា និងសម្ភារៈរូបវ័ន្តគ្រប់គ្រាន់ សម្រាប់រៀបចំការពារខ្លួន និងឆ្លើយឆ្លងជាមួយមេធាវីដែលជ្រើសរើសដោយខ្លួនឯង។

(គ) ត្រូវបានជំនុំជំរះដោយឥតពន្យារពេលយូរហួសហេតុ។

(ឃ) ត្រូវបានជំនុំជំរះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់ តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌ តម្រូវឱ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះបើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។

(ង) ត្រូវមានការសួរចម្លើយ ឬសុំឱ្យសួរចម្លើយ ទៅលើសាក្សីដាក់បន្ទុក និងសុំឱ្យសាក្សីដោះបន្ទុកចូលខ្លួន ដើម្បីសួរចម្លើយក្នុងនាមខ្លួន ក្នុងលក្ខខណ្ឌដូចគ្នា និងសាក្សីដាក់បន្ទុក។

(ច) ត្រូវទទួលបានអ្នកបកប្រែ ដោយឥតគិតឈ្នួល បើជនជាប់ចោទមិនយល់ ឬមិនចេះភាសាដែលប្រើប្រាស់ក្នុងសវនាការ។

(ឆ) មិនត្រូវបានបង្ខិតបង្ខំ ឱ្យឆ្លើយដាក់កំហុសលើខ្លួនឯង ឬសារភាពថាមានពិរុទ្ធ។

៤. នីតិវិធីអនុវត្តចំពោះយុវជន-យុវនារី ដែលមិនទាន់មាន នីតិភាពតាមច្បាប់កំណត់ត្រូវគិតដល់អាយុ និងអត្ថប្រយោជន៍នៃការអប់រំរបស់ពួកគេឡើងវិញ។

៥. ជនគ្រប់រូប ដែលជាប់ពិរុទ្ធពីបទល្មើសព្រហ្មទណ្ឌ ត្រូវមានសិទ្ធិសុំឱ្យសាលាក្តីជាន់ខ្ពស់ ពិនិត្យទៅលើការប្រកាសពិរុទ្ធភាព និងការផ្តន្ទាទោសឡើងវិញ ស្របតាមច្បាប់។

៦. នៅពេលជនណាម្នាក់ ត្រូវបានប្រកាសឱ្យជាប់ពិរុទ្ធពីបទព្រហ្មទណ្ឌជាស្ថាពរ ហើយក្រោយមក ការប្រកាសឱ្យជាប់ពិរុទ្ធនេះ ត្រូវបានបដិសេធ ឬត្រូវបានលើកលែងទោស ដោយហេតុថា អង្គហេតុថ្មី ឬដែលបានរកឃើញថ្មី បញ្ជាក់យ៉ាងច្បាស់ថា មានការខុសឆ្គងពីសំណាក់តុលាការ ជនដែលទទួលរងគ្រោះដោយសារការដាក់ទោសនេះ ត្រូវទទួលសំណងតាមច្បាប់ លើកលែងតែមានការកំណត់បង្ហាញថា ការមិនលាតត្រដាងអាថ៌កំបាំងនៃការពិតទាន់ពេលបណ្តាលមកពីជននោះទាំងស្រុង ឬមួយផ្នែក។

៧. គ្មានជនណាម្នាក់ ត្រូវយកមកចោទប្រកាន់ ឬយកមកផ្តន្ទាទោសសារជាថ្មីឡើយចំពោះបទល្មើសដែលបានផ្តន្ទាទោសជាស្ថានពរ ឬបានលើកលែងទោសស្របតាមនិតិវិធីព្រហ្មទណ្ឌ របស់រដ្ឋនីមួយៗរួចហើយ។

មាត្រា១៦

ជនគ្រប់រូបមានសិទ្ធឱ្យគេទទួលស្គាល់បុគ្គលិកលក្ខណៈគតិយុត្តិរបស់ខ្លួននៅគ្រប់ទីកន្លែង។

គ. គោលការណ៍យ៉កយ៉ាកាតា

គោលការណ៍៣

បុគ្គលគ្រប់រូប មានសិទ្ធិឱ្យគេទទួលស្គាល់នៅគ្រប់កន្លែង ថាជាមនុស្ស ចំពោះមុខច្បាប់។ បុគ្គលដែលមាននិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ខុសពីគេ មានសិទ្ធិស្របច្បាប់ នៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត។ និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ របស់បុគ្គលម្នាក់ៗ មានសារៈសំខាន់សម្រាប់បុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ ហើយក៏ជាទិដ្ឋភាពមូលដ្ឋាននៃការតាំងចិត្តផ្ទាល់ខ្លួន សេចក្ដីថ្លៃថ្នូរ និងសេរីភាព។ គ្មានជនណាម្នាក់ត្រូវបានបង្ខំឱ្យទទួលការព្យាបាលផ្នែកវេជ្ជសាស្ត្រ រួមទាំងការវះកាត់ប្ដូរភេទ ការព្យាបាលមិនឱ្យមានកូន ឬការព្យាបាលអ័រម៉ូន ដើម្បីទទួលបាននូវការទទួលស្គាល់ស្របច្បាប់ ចំពោះអត្តសញ្ញាណយេនឌ័រនោះទេ។ គ្មានស្ថានភាព ដូចជាអាពាហ៍ពិពាហ៍ ឬភាពជាឪពុកម្ដាយ ត្រូវបានគេស្នើឡើង ជាលក្ខខណ្ឌរារាំងការទទួលស្គាល់ស្របច្បាប់នៃអត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាមួយឡើយ។ គ្មានជនណាម្នាក់ត្រូវបានរងសម្ពាធឱ្យលាក់បាំងរងការទប់ស្កាត់ ឬបដិសេធអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់បុគ្គលនោះទេ។

រដ្ឋមានកាតព្វកិច្ចត្រូវ៖

ក. ធានាថា បុគ្គលគ្រប់រូប ត្រូវបានផ្ដល់សិទ្ធិស្របច្បាប់ ចំពោះបញ្ហាស៊ីវិល ដោយគ្មានការរើសអើងលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ហើយត្រូវបានផ្ដល់ឱកាស ប្រើប្រាស់សិទ្ធិទាំងនេះ រួមទាំងសិទ្ធិស្មើគ្នា ក្នុងការចុះកិច្ចសន្យា និងក្នុងការគ្រប់គ្រង ការធ្វើជាម្ចាស់កម្មសិទ្ធិ ការទទួលបាន (រួមទាំងការទទួលបានកេរ្ដិ៍មរតក) ការប្រើប្រាស់ចាត់ចែង និងស្រ័យផល។

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីគោរព និងទទួលស្គាល់ឱ្យបានពេញលេញ នូវសិទ្ធិស្របច្បាប់ ក្នុងការទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដោយផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ។

គ. ចាត់វិធានការ ខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាឱ្យបានថា នីតិវិធីដែលរដ្ឋចេញលិខិតស្នាម បញ្ជាក់អំពីភេទ/យេនឌ័រ

របស់បុគ្គលនីមួយៗ រួមមាន សំបុត្រកំណើត លិខិតឆ្លងដែន ឯកសារបោះឆ្នោត និងឯកសារផ្សេងទៀត ពិតជាឆ្លុះបញ្ចាំងពីអត្តសញ្ញាណយេនឌ័រ ដែលត្រូវបានកំណត់ដោយសាមីខ្លួននោះផ្ទាល់។

ឃ. ធានាថា នីតិវិធីទាំងនោះ មានប្រសិទ្ធភាព សុក្រិតភាព និងគ្មានការរើសអើង ព្រមទាំងគោរពនូវភាពថ្លៃថ្នូរ និងឯកទត្តភាពដល់បុគ្គលដែលពាក់ព័ន្ធ។

ង. ធានាថា រាល់ការកែប្រែឯកសារបញ្ជាក់អត្តសញ្ញាណ នឹងត្រូវបានទទួលស្គាល់ ក្នុងគ្រប់បរិបទទាំងអស់ នៅពេលដែលច្បាប់ ឬគោលនយោបាយនានា តម្រូវឱ្យមានការបញ្ជាក់ ឬវែកញែកអំពីយេនឌ័ររបស់បុគ្គល។

ច. អនុវត្តកម្មវិធីផ្សេងៗ ដែលមានគោលដៅផ្តល់ការគាំទ្រផ្នែកសង្គមកិច្ចដល់ជនទាំងឡាយណា ដែលធ្លាប់ឆ្លងកាត់ដំណាក់កាល ផ្លាស់ប្តូរឬបន្លាស់ប្តូរភេទ។

ឃ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ៧

មនុស្សទាំងអស់ មានភាពស្មើៗគ្នាចំពោះមុខច្បាប់ ហើយមានសិទ្ធិទទួលបាននូវ កិច្ច ការពា រ ដោ យ ច្បា ប់ដោយស្មើ ៗ គ្នាដោ យគ្មាន ការរើ សអើងណាមួយឡើយ។ មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវកិច្ចការពារខ្លួនស្មើៗគ្នា ប្រឆាំងទល់នឹងការរើសអើងណាមួយដែលជាការរំលោភនូវសេចក្តីប្រកាសនេះ និងប្រឆាំងទល់នឹងការញុះញង់ណាមួយដែលនាំទៅមានការរើសអើង។

មាត្រា ៨

មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវ ការដោះស្រាយដោយតុលាការជាតិ ដែលមានសមត្ថភាពចំពោះ អំពើទាំងឡាយដែលរំលោភសិទ្ធិសំខាន់ៗរបស់ខ្លួន ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ ឬដែលមានចែងនៅក្នុងច្បាប់។

## ៩. សិទ្ធិប្រឆាំងនឹងការឃុំខ្លួនដោយបំពាន

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា៣៩

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទារសំណងជួសជុលខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ។ ការដោះស្រាយបណ្តឹងតវ៉ា និងសំណងជួសជុលការខូចខាតជាសមត្ថកិច្ចរបស់តុលាការ។

ខ. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា៩

១. ជនគ្រប់រូប មានសិទ្ធិមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនិតីវិធីដែលមានចែងក្នុងច្បាប់។

២. ជនណាដែលត្រូវបានចាប់ខ្លួន ត្រូវមានសិទ្ធិឱ្យគេ ប្រាប់ឱ្យដឹងនៅពេលចាប់ខ្លួន អំពីមូលហេតុនៃការចាប់ខ្លួន និងត្រូវប្រាប់ឱ្យដឹងភ្លាមអំពីការចោទប្រកាន់។

៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និងត្រូវបានជំនុំជំរះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង។ ការឃុំខ្លួនមនុស្ស ដើម្បីរង់ចាំការជនុំជំរះ គឺមិនមែនជាវិធានការទូទៅទេ ប៉ុន្តែការឱ្យនៅក្រៅឃុំ ត្រូវតែមានការធានាការចូលខ្លួនរបស់ជននោះ នៅពេលសវនាការ ឬនៅគ្រប់ដំណាក់ការដទៃទៀតនៃនីតិវិធី ហើយត្រូវមានមុខក្នុងការ អនុវត្តន៍សាលក្រម។

៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវតែមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឱ្យតុលាការអាចសម្រេចដោយមិនពន្យារពេលអំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងការបង្គាប់ឱ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។

៥. ជនណាដែលបានរងគ្រោះដោយសារការឃាត់ខ្លួន ឬឃុំខ្លួន ដោយខុសច្បាប់ មានសិទ្ធិទាមទារសំណង។

គ. គោលការណ៍យ៉ុកយ៉ាកាតា

គោលការណ៍ ៧

គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬឃុំខ្លួនដោយបំពានបានឡើយ។ រាល់ការចាប់ខ្លួន ឬឃុំខ្លួន ដែលឈរលើមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មិនថាអនុលោមតាមដីកាតុលាការ ឬយ៉ាងណានោះទេ គឺជាសកម្មភាពបំពាន។ បុគ្គលគ្រប់រូបដែល ស្ថិតក្រោមការចាប់ខ្លួន ដោយមិនប្រកាន់ពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិស្មើៗគ្នាក្នុងការដឹងពីមូលហេតុនៃការចាប់ខ្លួន និងលក្ខខណ្ឌនៃការចោទប្រកាន់នានាមកលើខ្លួន ក្នុងការត្រូវបានគេនាំខ្លួនទៅចំពោះមុខមន្ត្រីចៅក្រមភ្លាមៗ និងក្នុងការទទួលបានការជំនុំជំរះ ដើម្បីកំណត់ពីភាព ស្របច្បាប់នៃការឃុំខ្លួន មិនថាត្រូវបានចោទប្រកាន់ពីបទល្មើសណាមួយ ឬយ៉ាងណានោះទេ។

រដ្ឋមានកាតព្វកិច្ចត្រូវ៖

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា និន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ទោះក្នុងកាលៈទេសៈណាក៏ដោយ នឹងមិនត្រូវបាន យកជាមូលដ្ឋាននៃការចាប់ខ្លួន ឬឃុំខ្លួននោះឡើយ នេះដោយរាប់ទាំងការលុបចោលបណ្តាបញ្ញត្តិច្បាប់ព្រហ្មទណ្ឌនានា ដែលប្រើពាក្យមិនច្បាស់លាស់ ជាហេតុអាចបង្កឱ្យមានការអនុវត្តច្បាប់ ដោយរើសអើងឬផ្តល់ឱកាសចាប់ខ្លួន ដោយឈរលើមូលដ្ឋាននៃចន្លោះប្រហោងច្បាប់បែបនេះ។

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាបុគ្គលគ្រប់រប ដែល ស្ថិតក្រោមការចាប់ខ្លួន ដោយមិនប្រកាន់ពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិស្មើៗគ្នា ក្នុងការដឹងពីមូលហេតុនៃការចាប់ខ្លួន និងលក្ខខណ្ឌនៃការចោទប្រកាន់នានាមកលើខ្លួន ក្នុងការត្រូវបានគេនាំខ្លួនទៅចំពោះមុខមន្ត្រីចៅក្រមភ្លាមៗ និងក្នុងការទទួលបានការជំនុំជំរះ ដើម្បីកំណត់ពីភាពស្របច្បាប់នៃការឃុំខ្លួន។

គ. បង្កើតកម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ដល់មន្ត្រីប៉ូលីស និងមន្ត្រីអនុវត្តច្បាប់ទាំងអស់ឱ្យយល់ថា ការចាប់ខ្លួន ឬឃុំខ្លួនដែលឈរ

មូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ គឺជាការបំពាន។

ឃ. រក្សាឱ្យបាននូវកំណត់ត្រា ដែលមានសុក្រឹតភាព និងត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ អំពីការចាប់ខ្លួន និងឃុំខ្លួនទាំងឡាយដោយបញ្ជាក់ពីកាលបរិច្ឆេទ ទីតាំង និងមូលហេតុនៃការឃុំខ្លួន ព្រមទាំងធានាថាឱ្យមានការត្រួតពិនិត្យទីតាំងឃុំឃាំងទាំងនោះ ដោយស្ថាប័នឯករាជ្យ ដែលត្រូវបានផ្តល់អាណត្តិ និងលទ្ធភាពគ្រប់គ្រាន់ ក្នុងការកំណត់លើរាល់ការចាប់ខ្លួន និងការឃុំខ្លួន ដែលអាចបណ្តាលមកពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័ររបស់បុគ្គលណាម្នាក់នោះ។

ឃ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ៩

គ្មានបុគ្គលណាម្នាក់ត្រូវទទួលរងការចាប់ខ្លួន ការឃុំឃាំងខ្លួន ឬ និរទេសខ្លួន តាមអំពើចិត្តបានឡើយ។

## ៥. សិទ្ធិទទួលបានសេវាសុខភាព និងសន្តិសុខសង្គម

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើស មុខរបរសមស្របតាមសម្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតំលៃស្មើគ្នា នឹងកំរៃដែលបានមកពីការងារក្រៅផ្ទះ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមានកំណត់ក្នុងច្បាប់។

មាត្រា ៧២

សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការពារ

ជម្ងឺ។ ប្រជារាស្ត្រក្រីក្រ ត្រូវបានទទួលការពិនិត្យរោគ ដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យគិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។

ខ. គោលការណ៍យ៉ូកយ៉ាកាតា

គោលការណ៍ ៥

បុគ្គលគ្រប់រូប ដោយមិនគិតពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ មានសិទ្ធិទទួលបានការការពារសុវត្ថិភាពបុគ្គល ហើយនិងសិទ្ធិទទួលបានកិច្ចការពារពីរដ្ឋ ប្រឆាំងរាល់អំពើហឹង្សា ឬការធ្វើឱ្យប៉ះពាល់ដល់រាងកាយ មិនថាពីសំណាក់មន្ត្រីរាជការ ឬបុគ្គល ឬក្រុមណាមួយក៏ដោយ។

រដ្ឋមានកាតព្វកិច្ចត្រូវ៖

ក. អនុវត្តរាល់គោលនយោបាយ និងវិធានការចាំបាច់ផ្សេងៗ ដើម្បីរារាំង និងផ្តល់ការការពារតបតនឹង គ្រប់ទម្រង់ទាំងអស់នៃអំពើហិង្សា និងការបៀតបៀនកេរ្តិ៍ខ្មាស់ ដែលជាប់ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

ខ. អនុវត្តវិធានការច្បាប់ចាំបាច់នានា ដើម្បីជំ រុ ញឱ្យមានការដាក់ទោសឧក្រិដ្ឋកម្មដ៏សមស្រប ចំពោះអំពើហិង្សា កា រគំរាមកំហែង ប្រើប្រាស់អំពើហិង្សា ការញុះញង់ បង្កឱ្យមានអំពើហិង្សា និ ង ការបៀតបៀនកេរ្តិ៍ខ្មាស់ ដែលឈរលើមូលដ្ឋាននិន្នាការភេទ និងអត្ត សញ្ញាណយេនឌ័ររបស់បុគ្គល ឬក្រុមណាមួយលើគ្រប់មជ្ឈដ្ឋាននៃជីវភាពរួមទាំងគ្រួសារផងដែរ។

គ. ចាត់វិធានការខាង នីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថា ជន រ ងគ្រោះពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នឹងមិនត្រូវបានគេយកមក ប្រើ ប្រាស់ដើម្បីជាសម្អាង ជាលេស ឬដើម្បីបន្ធូរបន្ថយបទអំពើហិង្សាទាំងនោះឡើយ។

ឃ. ត្រូវ ធា នាថា ការប្រព្រឹត្តអំពើហិង្សាទាំងឡាយត្រូវបានស៊ើបអង្កេតយ៉ាងតឹងរឹ ង ហើយក្នុងករណីដែលភស្តុតាង ត្រូវបានរកឃើញគ្រប់គ្រាន់នោះ ជនល្មើស នឹ ងត្រូវចាប់ផ្តន្ទាទោស កាត់ទោស និងដាក់ទោសសមស្រប ហើយជនរងគ្រោះ ត្រូវបានផ្តល់នូវការប៉ះប៉ូវ និងសំណងដែលខូចខាត រួមទាំងសំណងជាលុយផងដែរ។

ង. បង្កើតយុទ្ធនាការលើកកម្ពស់ ការយល់ដឹងដោយផ្ទាល់ ទៅកាន់សាធារណជនទូទៅ ក៏ដូចជាទៅកាន់ជនល្មើសប្រព្រឹត្តអំពើហឹង្សាជាក់ស្តែង និងដែល ត្រូវបានកត់សម្គាល់ ក្នុងគោលបំណងដើម្បីប្រយុទ្ធប្រឆាំងនឹង គំនិតបុរេនិ- ច្ច័យ ដែលបណ្តាលឱ្យមានអំពើហិង្សា ទាក់ទងនឹងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

គោលការណ៍ ១២

មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវ និងពេញចិត្ត និងមានកិច្ចការពារប្រឆាំងនឹងភាពអត់ការងារធ្វើ ដោយមិនមានការរើសអើង ពីហេតុនៃនិន្នាការភេទ ឬអត្តយេនឌ័រនោះឡើយ។

រដ្ឋមានកាតព្វកិច្ច

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីលុបបំបាត់ និងហាមឃាត់ការរើសអើងទៅលើនិន្នការភេទ និងអត្តសញ្ញាណយេនឌ័រ ទាំងសម្រាប់ការងារសាធារណៈ និងឯកជន ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលការងារ ការជ្រើសរើសបុគ្គលិក ការតម្លើងឋានៈ ការ បញ្ឈប់ពីការងារ លក្ខខណ្ឌការងារ និងការទទួលបានលាភការ។

ខ. លុបបំបាត់ការរើសអើងផ្សេងៗ ដោយសារមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដើម្បីធានាថា បុគ្គលម្នាក់ៗ អាចទទួលបានការងារ និងឱកាសអភិវឌ្ឍខ្លួន ក្នុងគ្រប់វិស័យសេវាកម្មសាធារណៈ ដោយរួមបញ្ចូលទាំងសេវាកម្មរដ្ឋាភិបាល និងការងារក្នុងមុខងារសាធារណៈ ដូចជាការបម្រើការងារជាមន្ត្រីប៉ូលីស និងយោធា និងផ្តល់កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដ៏សមស្រប ដើម្បីប្រឆាំងនឹងឥរិយាបថរើសអើង។

គោលការណ៍ ១៧

បុគ្គលគ្រប់រូប មានសិទ្ធិទទួលបានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបានដោយ គ្មានការរើសអើង ពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ។ សុខភាពផ្លូវភេទ និង

សុខភាពបន្តពូជ គឺជាទិដ្ឋភាពមូលដ្ឋាននៃសិទ្ធិនេះ។

រដ្ឋមានកាតព្វកិច្ចត្រូវ៖

ក. ចាត់វិធានការខាងនីតិបញ្ញត្តិខាងរដ្ឋបាលនិងវិធានការផ្សេងទៀតដើម្បីធានាសម្រេចបាន ការប្រើប្រាស់ពេញលេញនូវសិទ្ធិទទួលបានកម្រិតសុខភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបានដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ។

ខ. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀត ដើម្បីធានាថាបុគ្គលគ្រប់រូបទទួលបាន សេវាថែទាំសុខភាព ទំនិញ និងសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ ហើយកំណត់ត្រាសុខភាពផ្ទាល់ខ្លួន របស់ពួកគេ ដោយគ្មានការរើសអើងពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

គ. ធានាថាសេវាថែទាំសុខភាព ទំនិញ និងសេវាកម្មផ្សេងៗ ត្រូវបានបង្កើតឡើងដើម្បីជួយលើកកម្ពស់ ស្ថានភាពសុខភាព និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សគ្រប់រូបដោយគ្មានការរើសអើងពីនិន្នការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ ហើយព្រមទាំងធានាថា រាល់កំណត់ត្រាព្យាបាលរបស់បុគ្គលម្នាក់ៗ ត្រូវបានរក្សាភាពសម្ងាត់។

ឃ. បង្កើត និងអនុវត្តកម្មវិធីនានា ដើម្បីដោះស្រាយបញ្ហារើសអើង គំនិតបុរេវិនិច្ឆ័យ និងកត្តាសង្គមផ្សេងទៀត ដែលបង្កមហន្តរាយដល់សុខភាពមនុស្សពីហេតុនៃនិន្នការភេទ ឬអត្តសញ្ញាណយេនឌ័រ។

ង. ធានាថា បុគ្គលគ្រប់រូប ទទួលបានព័ត៌មាន និងមានអំណាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ទាក់ទងនឹងការថែទាំ និងការព្យាបាលវេជ្ជសាស្ត្រ ដោយផ្អែ កលើពត៌មានពិតប្រាកដដដែល ទទួលបានដោយគ្មានការរើសអើងពីនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រនោះឡើយ។

ច. ធានាថា រាល់បញ្ហាសុខភាពផ្លូវភេទ និងសុខភាពបន្តពូជ ការអប់រំការ ទប់ស្កាត់ កម្មវិធីព្យាបាល និងសេវាថែទាំ និងសេវាកម្មផ្សេងទៀត ផ្តោតលើភាពចម្រុះបែបនៃនិន្នាការភេទ និងអត្តញ្ញាណយេនឌ័រ ហើយរាល់សេវាកម្មទាំងនេះ

ត្រូវបានផ្តល់ជូនដល់បុគ្គលិកគ្រប់រូបស្មើគ្នា ដោយគ្មានការរើសអើង។

ឆ. ផ្តល់ភាពងាយស្រួលដល់បុគ្គលទាំងឡាយណា ដែលស្វែងរកការកែប្រែរាងកាយ ដែលជាប់ទាក់ទងនឹង ការវះកាត់ប្តូរភេទ ក្នុងការទទួលបានការព្យាបាល ការថែទាំ និងគាំទ្រយ៉ាងពេញសមត្ថភាព និងគ្មានការរើសអើង។

ជ. ធានាថារាល់អ្នកផ្តល់សេវាសុខភាពទាំងអស់ ប្រព្រឹត្តមកលើអតិថិជន និងដៃគូររបស់ពួកគេ រួមទាំងអ្នកដែលចាត់ទុកថាជាញាតិសន្តាន ជំនាន់ក្រោយ ដោយគ្មានការរើសអើងលើនិន្នការភេទ ឬអត្តសញ្ញាណយេ-នឌ័រនោះឡើយ។

ឈ. អនុម័តគោលនយោបាយ និងកម្មវិធីអប់រំនិងបណ្តុះបណ្តាល ដែលចាំបាច់អាចធ្វើឱ្យអ្នកដែលធ្វើការលើវិស័យសុខភាព អាចផ្តល់កម្រិតថែទាំសុខភាពខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន ចំពោះបុគ្គលគ្រប់រូប ប្រកបដោយការគោរពចំពោះនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។

គ. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ២៣

១. មនុស្សគ្រប់រូប មានសិទ្ធិធ្វើការងារ មានសិទ្ធិជ្រើសរើសការងារ និងមានសិទ្ធិធ្វើការងារក្នុងលក្ខណៈត្រឹមត្រូវ និងគួរពេញចិត្ត ព្រមទាំងមានសិទ្ធិទទួលបាននូវកិច្ចការពារទល់នឹងភាពឥតមានការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នា សម្រាប់ទង្វើការងារដូចគ្នា ដោយឥតមានការរើសអើងអ្វីឡើយ។

៣. ជនដែលធ្វើការងារ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ត្រឹមត្រូវ និងគួរពេញចិត្តដើម្បីធានាជីវភាពរស់នៅរបស់គេនិងគ្រួសារ គេឱ្យមាននូវតម្លៃនៃសេចក្តីថ្លៃថ្នូររបស់មនុស្សហើយត្រូវបានបំពេញបន្ថែមតាមមធ្យោបាយការពារផ្នែកសង្គមផ្សេងៗទៀត ប្រសិនបើមានការចាំបាច់។

៤. មនុស្សគ្រប់រូប មានសិទ្ធិបង្កើតសហជីព និងមានសិទ្ធិចូលជាសមាជិកនៃសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

មាត្រា ២៥

១. មនុស្សគ្រប់រូប មានសិទ្ធិទទួលបាននូវជីវភាព គ្រប់គ្រងតាមបទដ្ឋាន

សម្រាប់សុខភាព និងសុខុមាលភាពរបស់គេ និងគ្រួសារគេ មានជាអាទិ៍ ចំណីអាហារ សំលៀកបំពាក់ លំនៅឋាន ការថែទាំសុខភាព និងសេវាសង្គមកិច្ចចាំបាច់ផ្សេងៗទៀត ព្រមទាំងសិទ្ធិទទួលបាននូវសន្តិសុខក្នុងពេល គ្មានការងារធ្វើ ពេលមានជម្ងឺ ពេលធ្លាក់ខ្លួនពិការ ពេលប្ដូរភាពជាមេម៉ាយឬពោះម៉ាយ ពេលចាស់ជរា ឬការខ្វះខាតខាងជីវភាពដទៃៗទៀតក្នុងកាលៈទេសៈដែលហួសពីភាពម្ចាស់ការរបស់គេ។

២. មាតុភាព និងកុមារភាព មានសិទ្ធិទទួលបាននូវការថែទាំ និងជួយទំនុកបម្រុង ពិសេស។ គ្រប់កុមារទាំងអស់ ទោះកើតពីឪពុកម្ដាយរៀបអាពាហ៍ពិពាហ៍នឹងគ្នាក្ដី ឬមិនបានរៀបអាពាហ៍ពិពាហ៍ក្ដី ត្រូវបានទទួលកិច្ចការសង្គមកិច្ចដូចគ្នា ។

ឃ. កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

មាត្រា៩

រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់ជនគ្រប់រូប ទទួលបានសន្តិសុខសង្គម រួមទាំងការធានារ៉ាប់រងសង្គមផង។

មាត្រា១២

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបមានកម្រិតសុខភាព ទាំងខាងរាងកាយ និងខាងស្មារតីខ្ពស់បំផុត តាមដែលអាចធ្វើទៅបាន។

២. វិធានការនានា ដែលរដ្ឋភាគីនៃកតិកាសញ្ញានេះចាត់ ដើម្បីធានាការប្រើសិទ្ធិនេះឱ្យបានពេញលេញ ត្រូវរាប់បញ្ចូលនូវវិធានការដែលចាំបាច់ដើម្បីធានា៖

(ក) វិធានការសម្រាប់ការកាត់បន្ថយអត្រាមរណៈ នៃទារកក្នុងពោះម្ដាយ និងមរណៈនៃកុមារ និងសម្រាប់ការរីកលូតលាស់ប្រកបដោយសុខភាពល្អរបស់កុមារ។

(ខ) ការធ្វើឱ្យប្រសើរគ្រប់ទិដ្ឋភាព នៃអនាម័យខាងផ្ទែកបរិស្ថាន និងឧស្សាហកម្ម។

(គ) វិធីបង្ការ ការព្យាបាល និងការត្រួតពិនិត្យជម្ងឺឆ្លង ជម្ងឺរាតត្បាត ជម្ងឺបណ្តាលមកវិជ្ជាជីវៈ និងជម្ងឺដទៃទៀត ព្រមទាំងប្រយុទ្ធប្រឆាំង នឹងជម្ងឺទាំងនេះផង។

(ឃ) ការបង្កើតលក្ខខណ្ឌ សម្រាប់ធានាដល់ជនគ្រប់រូប នូវសេវាសុខាភិបាលគ្រប់ផ្នែក និងជំនួយផ្នែកសុខាភិបាលក្នុងពេលមានជម្ងឺ។

## ៦. សិទ្ធិមានការងារ

ក. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

មាត្រា ៣៦

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាម សម្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតំលៃស្មើគ្នានឹងកំរៃដែលបានមកពីការងារក្រៅផ្ទះ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិបង្កើតសហជីពនិងចូលជាសមាជិកសហជីពនេះ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីពនឹងមាបកំណត់ក្នុងច្បាប់។

ខ. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

មាត្រា ២៣

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើការងារ មានសិទ្ធិជ្រើសរើសការងារ និងមានសិទ្ធិធ្វើការងារក្នុងលក្ខណៈត្រឹមត្រូវ និងគួរពេញចិត្ត ព្រមទាំងមានសិទ្ធិទទួលបាននូវកិច្ចការពារទល់នឹងភាពឥតមានការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នាសម្រាប់ទង្វើការងារដូចគ្នា ដោយឥតមានការរើសអើងអ្វីឡើយ។

៣. ជនដែលធ្វើការងារ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ត្រឹមត្រូវ និងគួរពេញចិត្ត ដើម្បីធានាជីវភាពរស់នៅរបស់គេ និងគ្រួសារគេឱ្យមាននូវតម្លៃនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវបានបំពេញបន្ថែម តាមមធ្យោបាយការពារផ្នែកសង្គមផ្សេងៗទៀត ប្រសិនបើមានការចាំបាច់។

៤. មនុស្សគ្រប់រូបមានសិទ្ធិបង្កើតសហជីព និងមានសិទ្ធិចូលជាសមាជិកនៃសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

គ. គោលការណ៍យ៉កយ៉ាកាតា

គោលការណ៍ ១២

ម នុស្សគ្រ ប់រូប មានសិទ្ធិទទួលបានការងារធ្វើ ជ្រើសរើសការងារដោយសេរី ទទួលបានលក្ខខណ្ឌការងារត្រឹមត្រូវនិងពេញចិត្ត និងមានកិច្ចការពារប្រឆាំងនឹងភាពអ ត់ការងារធ្វើ ដោយមិនមានការរើសអើង ពីហេតុនៃនិន្នាការភេទ ឬអត្តយេនឌ័រនោះឡើយ។

រដ្ឋមានកាតព្វកិច្ច

ក. ចាត់វិធានការខាងនីតិបញ្ញត្តិ ខាងរដ្ឋបាល និងវិធានការផ្សេងទៀតដើម្បីលុបបំបាត់ និងហាមឃាត់ការរើសអើងទៅលើនិន្នការភេទ និងអត្តសញ្ញាណយេនឌ័រ ទាំងសម្រាប់ការងារសាធារណៈនិងឯកជន ដែលរួមបញ្ចូលទាំងការបណ្តុះបណ្តាលការងារ ការជ្រើសរើសបុគ្គលិក ការតម្លើងឋានៈ ការបញ្ឈប់ពីការងារ លក្ខខណ្ឌការងារ និងការទទួលបានលាភការ។

ខ. លុបបំបាត់ការរើសអើងផ្សេងៗ ដោយសារមូលដ្ឋាននៃនិន្នាការភេទ ឬអត្តសញ្ញាណយេនឌ័រ ដើម្បីធានាថា បុគ្គលម្នាក់ៗអាចទទួលបានការងារ និងឱកាសអភិវឌ្ឍខ្លួនក្នុង គ្រប់វិស័យសេវាកម្មសាធារណៈ ដោយរួមបញ្ចូលទាំងសេវាកម្មរដ្ឋាភិបាល និងការងារក្នុងមុខងារសាធារណៈ ដូចជាការបម្រើការងារជាមន្ត្រីប៉ូលីស និងយោធា និងផ្តល់កម្មវិធីបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងដ៏សមស្រប ដើម្បីប្រឆាំងនឹងឥរិយាបថរើសអើង។

ឃ.សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស

មាត្រា ២៣

១. មនុស្សគ្រប់រូបមានសិទ្ធិធ្វើការងារ មានសិទ្ធិជ្រើសរើសការងារ និងមានសិទ្ធិធ្វើការងារក្នុងលក្ខណៈត្រឹមត្រូវ និងគួរពេញចិត្ត ព្រមទាំងមានសិទ្ធិទទួលបាននូវកិច្ចការពារទល់នឹងភាពឥតមានការងារធ្វើ។

២. មនុស្សគ្រប់រូប មានសិទ្ធិទទួលប្រាក់បៀវត្សរ៍ស្មើគ្នាសម្រាប់ទង្វើការងារ

ដូចគ្នា ដោយឥតមានការរើសអើងអ្វីឡើយ។

៣. ជនដែលធ្វើការងារ មានសិទ្ធិទទួលបាននូវប្រាក់បំណាច់ត្រឹមត្រូវ និងគួរពេញចិត្ត ដើម្បីធានាជីវភាពរស់នៅរបស់គេ និងគ្រួសារគេ ឱ្យមាននូវតម្លៃនៃសេចក្តីថ្លៃថ្នូររបស់មនុស្សហើយត្រូវបានបំពេញបន្ថែមតាមមធ្យោបាយការពារផ្នែកសង្គមផ្សេងៗទៀត ប្រសិនបើមានការចាំបាច់។

៤. មនុស្សគ្រប់រូបមានសិទ្ធិបង្កើតសហជីព និងមានសិទ្ធិចូលជាសមាជិកនៃសហជីព ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

ង. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

មាត្រា៧

រដ្ឋភាគីនៃកតិកាសញ្ញានេះទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបដើម្បីទទួលបាននូវលក្ខខណ្ឌការងារត្រឹមត្រូវ និងប្រកបដោយអំណោយផល ដែលធានាជាពិសេសនូវៈ

(ក) ប្រាក់កម្រៃដែលផ្តល់ជាអប្បបរមាឱ្យអ្នកធ្វើការនូវៈ

១. បៀវត្សរ៍ប្រកបដោយសមធម៌ និងប្រាក់កម្រៃស្មើគ្នាចំពោះការងារដែលមា នតម្លៃស្មើគ្នា ដោយមិនមានការបែងចែកណាមួយ ជាពិសេស ស្ត្រីត្រូវតែមានការធានានូវលក្ខខណ្ឌការងារ ដែលផ្តល់ឱ្យពួកគេ មិនតិចជាងលក្ខខណ្ឌដែលបុរសបានទទួល ដោយត្រូវបានប្រាក់កម្រៃស្មើគ្នា ចំពោះការងារដូចគ្នា។

២. ជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនគេផ្ទាល់ និងគ្រួសារ ស្របតាមបទបញ្ញត្តិនៃកតិកាសញ្ញានេះ។

(ខ) លក្ខខណ្ឌការងារប្រកបដោយសុវត្ថិភាព និងអនាម័យ។

(គ) ឱកាសដូចគ្នាសម្រាប់បុគ្គលគ្រប់រូប ដើម្បីបានឡើងឋានៈក្នុងការងារទៅកម្រិតខ្ពស់សមស្រប ដោយមិនពិចារណាទៅលើអ្វីផ្សេងពីអតីតភាពការងារ និងសមត្ថភាព។

(ឃ) ការសម្រាក ការលំហែ ការកម្រិតម៉ោងធ្វើការសមរម្យ និងការឈប់សម្រាកតាមកាលកំណត់ទៀងទាត់ ដោយមានប្រាក់បៀវត្សរ៍ និងប្រាក់កម្រៃសម្រាប់ថ្ងៃបុណ្យជាតិ។

មាត្រា៨

១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាធានាឱ្យបាននូវៈ

(ក) សិទ្ធិសម្រាប់ជនគ្រប់រូប បង្កើតសហជីព និងចូលរួមសហជីព តាមការជ្រើសរើសរបស់ខ្លួន ដោយស្ថិតក្រោមវិធានទាំងឡាយ ដែលកំណត់ដោយអង្គការពាក់ព័ន្ធ ដើម្បីលើកស្ទួយ និងការពាផលប្រយោជន៍សេដ្ឋកិច្ច និងសង្គមកិច្ចរបស់ខ្លួន។ ការប្រើប្រាស់សិទ្ធិនេះមិនអាចរឹតត្បិតបានទេ លើកលែងតែការរឹតត្បិតនោះ មានចែងនៅក្នុងច្បាប់ និងជាវិធានការចាំបាច់ ក្នុងសង្គមប្រជាធិបតេយ្យ ជាផលប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

(ខ) សិទ្ធិរបស់សហជីពបង្កើតសហព័ន្ធ ឬសម្ព័ន្ធជាតិ និងសិទ្ធិរបស់សហព័ន្ធ និងសម្ព័ន្ធជាតិ បង្កើត ឬចូលរួមក្នុងអង្គការសហជីពអន្តរជាតិ។

(គ) សិទ្ធិរបស់សហជីព ធ្វើសកម្មភាពដោយសេរីដោយគ្មានកម្រិតព្រំដែន លើកលែងតែ កម្រិតព្រំដែននោះមានចែងក្នុងច្បាប់ និងជាវិធានការចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ សម្រាប់ជាផលប្រយោជន៍ដល់សន្តិសុខជាតិឬសណ្តាប់ធ្នាប់សាធារណៈ ឬដើម្បីការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ។

(ឃ) សិទ្ធិធ្វើកូដកម្ម ដែលត្រូវប្រើប្រាស់ឱ្យស្របតាមច្បាប់ របស់ប្រទេសនីមួយៗ។

២. មាត្រានេះ មិនរារាំងដល់ការដាក់ការរឹតត្បិតស្របច្បាប់លើការប្រើប្រាស់សិទ្ធិទាំងនេះ ដោយសមាជិកកងកម្លាំងប្រដាប់អាវុធ ឬនគរបាល ឬមុខងារសាធារណៈឡើយ។

៣. គ្មានបទបញ្ញត្តិណាមួយនៃមាត្រានេះ អនុញ្ញាតឱ្យរដ្ឋភាគីទាំងអស់នៃអនុសញ្ញាឆ្នាំ១៩៤៨ នៃអង្គការពលកម្មអន្តរជាតិស្តីពីសេរីភាពខាងសហជីព និងការការពារសិទ្ធិសហជីព ចាត់វិធានការខាងផ្លូវច្បាប់ដែលប៉ះពាល់ ឬអនុវត្តច្បាប់តាមបែបដែលធ្វើឱ្យប៉ះពាល់ដល់ការធានាទាំង ឡាយដែលមានចែងក្នុងអនុសញ្ញានេះ។

